**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម**
**សាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន ពាមជីកង**

# ស្នាដៃចូលរួមអបអរសាទរទិវាជាតិអំណានលើកទី៩

## ប្រធានបទ

## “ តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ ”

បេក្ខជន **ឃុយ ម៉េងឃី** ភេទប្រុស កើតថ្ងៃទី៧ ខែមករា ឆ្នាំ១៩៩០
ទីកន្លែងកំណើត : ភូមិពង្រ ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម
ជាគ្រូបង្រៀនសាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន ពាមជីកង ខេត្តកំពង់ចាម
លេខទូរសព្ទ : ០១០ ៣២២ ២៣៤

**ព.ស.២៥៦៧** **គ.ស.២០២៤**

# មាតិកា


**I - សេចក្តីផ្តើម** ........................................................................ ១

**II- សាវតារនៃព្រះពុទ្ធសាសនានៅកម្ពុជា**.................................................. ២

១- ការមកដល់នៃព្រះពុទ្ធសាសនា........................................................... ២

២- អត្ថន័យនៃពាក្យ "ព្រះពុទ្ធសាសនា" ..................................................... ២

**III- តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌**..... ៣

**១- តួនាទីព្រះពុទ្ធសាសនាចំពោះបុគ្គល**........................................................ ៣

១.១- ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌បុគ្គល.................................. ៣

១.១.១- សីលប្រាំ ឬនិច្ចសីល.............................................................. ៣

១.១.២- កុសលកម្មបថ១០ប្រការ ......................................................... ៧

១.១.៣- អរិយសច្ចៈ ........................................................................ ៨

១.២- ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ចំពោះគ្រួសារ........................ ៩

១.២.១- ព្រហ្មវិហារធម៌មាតាបិតាចំពោះបុត្រធីតា ........................................ ៩

១.២.២- ភាពកតញ្ញូនៃបុត្រធីតាចំពោះមាតាបិតា ......................................... ១០

១.២.៣- សីលធម៌រវាងប្រពន្ធ-ប្តី ............................................................ ១២

១.៣- ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ចំពោះវិជ្ជាជីវៈ ...................... ១២

១.៤- ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌វិជ្ជាជីវៈចំពោះសង្គម ................ ១៣

**២- តួនាទីព្រះពុទ្ធសាសនាចំពោះសង្គម**....................................................... ១៤

២.១- ពុទ្ធសាសនា ព្រះសង្ឃ និងវត្តអារាម....................................................... ១៤

២.២- ព្រះពុទ្ធសាសនា និងសាលារៀន ........................................................... ១៦

២.៣- ព្រះពុទ្ធសាសនា និងកិច្ចអភិវឌ្ឍប្រទេសជាតិ.............................................. ១៧

**IV- សន្និដ្ឋាន** .................................................................................. ១៧

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**(**រូបភាព-ឯកសារ**)

## ប្រធានបទ
## តួនាទីព្រះពុទ្ធសាសនា
## ក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌

### I- សេចក្តីផ្តើម

ខ្មែរជាប្រជាជាតិមួយដែលធ្លាប់មានអរិយធម៌រុងរឿងនាសម័យមហានគរ។ ប្រការនេះ ជាហេតុនាំឱ្យជាតិខ្មែរពោរពេញទៅដោយមរតក សម្បត្តិវប្បធម៌ ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់យ៉ាងច្រើនសម្បូរបែបអនេកអនន្ត។ ក៏ប៉ុន្តែភាពល្អត្រចះត្រចង់ទាំងនេះ បានរងនូវការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរនៅក្នុងរបបអាវខ្មៅ សាហាវយង់ឃ្នង ដែលអូសបន្លាយអស់រយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ។ ជំនឿ សាសនា ប្រពៃណីទំនៀមទម្លាប់ដ៏ល្អផូរផង់របស់ជាតិ ត្រូវបនប្រល័យពូជសាសន៍ប៉ុលពត បំផ្លិចបំផ្លាញ និងលុបបំបាត់ចោលទាំងស្រុង។ សាសនាព្រះពុទ្ធដែលប្រជាជនខ្មែរតែងគោរពបូជាយ៉ាងមុតមាំ និងលើកតម្កើងនោះ ត្រូវបានពួកវាលុបបំបាត់ចោលទាំងស្រុង ដោយផ្សឹកព្រះសង្ឃក្នុងសំណាក់ព្រះពុទ្ធសាសនា ឱ្យទៅធ្វើស្រែចម្ការនៅតំបន់មូលដ្ឋានជនបទ [1] ។ វិស័យវប្បធម៌ និងហេដ្ឋារចនាសម្ព័ន្ធសង្គម ត្រូវបានបំផ្លិចបំផ្លាញចោលទាំងស្រុងក្នុងរបបដ៏ខ្មៅងងឹតមួយនេះ។

លុះក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ កម្ពុជាបានខិតខំកសាងប្រទេសជាតិឡើងវិញជាបន្តបន្ទាប់ ព្រោះថាកម្ពុជាបានរងនូវការខ្ទេចខ្ទាំស្ទើរតែទាំងអស់ ពោលគឺវិនាសគ្រប់ហេដ្ឋារចនាសម្ព័ន្ធ សូម្បីតែវិស័យសាសនា។ ដូច្នេះ អ្វីដែលកម្ពុជាត្រូវធ្វើ គឺខិតខំកសាងឡើងវិញពីបាតដៃទទេស្អាត។ ចាប់ពីពេលនោះហើយដែលព្រះពុទ្ធសាសនាកម្ពុជាបានរស់រានមានជីវិតឡើងវិញ។ ចំណែកឯសេរីភាពខាងជំនឿសាសនាក៏ត្រូវបានបើកចំហរ។ ប្រជាជនខ្មែរមានសិទ្ធិពេញលេញក្នុងផ្នែកសាសនា ដោយ "**សាសនាព្រះពុទ្ធត្រូវបានកំណត់ថាជាសាសនារបស់រដ្ឋ**" [2]។

មិនត្រឹមតែជាសាសនារបស់រដ្ឋនោះទេ មកទល់នឹងពេលបច្ចុប្បន្ននេះ ព្រះពុទ្ធសាសនាបានក្លាយទៅជាវប្បធម៌ជាតិរបស់ខ្មែរក្នុងការកំណត់វិថីជីវិតរបស់ខ្មែរតាំងពីកើតរហូតដល់ស្លាប់។ ជីវិតក្នុងក្រុមគ្រួសារ ការសិក្សាអប់រំ សិល្បៈ នយោបាយដឹកនាំប្រទេស សុទ្ធតែទទួលឥទ្ធពលពីព្រះពុទ្ធសាសនា ហើយឥទ្ធិពលនេះនឹងនៅតែបន្តទៅអនាគតទៀតជានិច្ចកាល [3] ។ ដូច្នេះ យើងអាចនិយាយបានថា ព្រះពុទ្ធសាសនាបានចាក់ចូលយ៉ាងជ្រៅទៅក្នុងក្រអៅបេះដូងមនុស្សខ្មែរ និងបានចូលរួមវិភាគទានយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គមកម្ពុជា ជាពិសេសគឺជាកម្លាំងជួយជំរុញ បណ្តុះបណ្តាល និងលើកកម្ពស់គុណភាពនៃការរស់នៅលើផ្នែកអប់រំសីលធម៌ និងចរិយាធម៌នៃមនុស្សជាតិ។

---

[1] *គោលការណ៍ទី៤ ក្នុងចំណោមគោលការណ៍ទាំង៨ចំណុចរបស់ខ្មែរក្រហម*

[2] *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា៤៣*

[3] *អ៊ីវ ចុង, អរិយធម៌ខ្មែរ, ២០១៥, ទំ.៣៨*

## II- សាវតារនៃព្រះពុទ្ធសាសនានៅកម្ពុជា

### ១- ការមកដល់នៃព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាបានចូលមកប្រតិស្ឋានក្នុងប្រទេសកម្ពុជា តាមរយៈសមណទូតពីរអង្គគឺ ព្រះសោណត្ថេរ និងឧត្តរត្ថេរ ដែលបាននាំចូលមកកាន់សុវណ្ណភូមិក្នុងពុទ្ធសករាជ២៣៤មុនគ្រិស្តសករាជ ក្រោមសាសនូបត្ថម្ភនៃព្រះបាទធម្មាសោកមហារាជ ដែលជាអ្នកកាន់ពុទ្ធសាសនាដ៏មុតមាំនៅក្នុងប្រទេសឥណ្ឌា [4] ។ បើតាមសិលាចារឹកវ៉ូកាញ់ ខេត្តញ៉ាត្រាង ព្រះពុទ្ធសាសនាទំនងជាចូលមកក្នុងប្រទេសកម្ពុជានៅសតវត្សរ៍ទី២នៃគ្រិស្តសករាជក្នុងរជ្ជកាលព្រះបាទហ្វាន់ចេរម៉ង ឬស្រីមារៈ [5] ។ តាមពិតទៅ មុនកាលមកដល់នៃអរិយធម៌ឥណ្ឌានេះ បុព្វជនខ្មែរមានជំនឿដើមរបស់ខ្លួនរួចទៅហើយ ដោយជឿលើព្រលឹងដូនតា អារុក្ខអារក្ស អ្នកតាព្រៃភ្នំក្រំថ្ម ជាទីពឹងសម្រាប់បង្រ្កាបភាពភ័យខ្លាច តក់ស្លុតរបស់ខ្លួនដែលជាទំនៀមរបស់ខ្មែរ។ លុះក្រោយមក ខ្មែរក៏យល់ឃើញថា ព្រះពុទ្ធសាសនាអាចជាទីពំនឹងពឹងពាក់ដល់ខ្លួនបាន។ អាស្រ័យហេតុនេះ ខ្មែរក៏ទទួលយកជ្រួតជ្រាបក្នុងសន្តានចិត្តរបស់ខ្លួនតៗមក ឥតសាបសូន្យឡើយ។ ចាប់តាំងពីពេលនោះមក ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជាក៏ស្ថិតស្ថេរគង់វង្សជាដរាប ទោះបីក្នុងសម័យខ្លះចុះអន់ថយ សម័យខ្លះសាបសូន្យក៏ដោយ។

តាមរយៈប្រវត្តិសាស្រ្តប្រទេសកម្ពុជា គេឃើញព្រះពុទ្ធសាសនាថេរវាទមានការលូតលាស់ជាងព្រះពុទ្ធសាសនាមហាយានតាំងពីដើមរហូតដល់បច្ចុប្បន្ន លើកលែងតែចុងសតវត្សរ៍ទី១២ ដល់ដើមសតវត្សរ៍ទី១៣ នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ដែលព្រះអង្គគោរពព្រះពុទ្ធសាសនាមហាយាន។ ក្រោយមក ប្រជាជនខ្មែរ រួមទាំងអ្នកដឹកនាំប្រទេស បាននាំគ្នាងាកមកគោរពព្រះពុទ្ធសាសនាថេរវាទវិញ ពីព្រោះខ្មែរយល់ថា ព្រះពុទ្ធសាសនាថេរវាទនេះ អាចជាទីពឹងបាន និងជឿជាក់ថា អាចនាំមនុស្សទៅរកសេចក្តីសុខបាន។

### ២- អត្ថន័យនៃពាក្យ "ព្រះពុទ្ធសាសនា"

ពាក្យថា "សាសនា" នៅក្នុងនិយមន័យរបស់វចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត មកពីពាក្យបាលីថា "សាសនៈ" បានសេចក្តីថា *ពាក្យបណ្តាំ ពាក្យផ្តាំផ្ញើ ពាក្យប្រៀនប្រដៅ ការប្រៀនប្រដៅ សាសនា លទ្ធិ ពាក្យបង្គាប់ ការបង្គាប់បញ្ជា ដំណឹង សំបុត្រ ពាក្យប្រកាស ការប្រកាសប្រាប់ ការជឿស្តាប់ ការដាក់ទណ្ឌកម្ម ការផ្ចាលទោស ការកែសម្រួល ការគ្រប់គ្រង ការត្រួតត្រា* [6]។ ដូច្នេះ ព្រះពុទ្ធសាសនា គឺបានដល់ពាក្យបណ្តាំ ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធបរមគ្រូនៃយើង។ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធហៅថា "ព្រះធម៌" ដែលព្រះអង្គទ្រង់សម្តែងអស់កាល៤៥ព្រះវស្សា មានដល់ទៅ៨៤០០០ធម្មក្ខន្ធ ឬ ៨៤០០០ន័យ។ ក្នុងព្រះពុទ្ធសាសនា ព្រះត្រៃបិដកជាគម្ពីរដែលផ្ទុកនូវពុទ្ធវចនៈដែលមាន១១០ភាគ គឺវិន័យបិដក(១៣ភាគ ២១០០០ធម្មក្ខន្ធ) សុត្តន្តបិដក(៦៤ភាគ ២១០០០ធម្មក្ខន្ធ) និងអភិធម្មបិដក(៣៣ភាគ ៤២០០០ធម្មក្ខន្ធ)។ ព្រះធម៌ គឺព្រះពុទ្ធទ្រង់ស្វែងរកឃើញ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយព្រះអង្គឯងផ្ទាល់ ជាសច្ចធម៌

---

[4] *ព្រះមហាវិរិយបណ្ឌិតោ ប៉ាង ខាត់, ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥០៤, ទំ.៣*

[5] *លាង ហាប់អាន, ប្រវត្តិអក្សរសាស្រ្តខ្មែរ, បណ្ណាគារគីមអេង, ១៩៦៧, ទំ.១៩*

[6] *ជួន ណាត, វចនានុក្រមខ្មែរ, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧, ទំ.១៣៤៣*

ហើយសច្ចធម៌នេះមានសច្ចភាពណាស់ ដូចបាលីថា "*នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស*" ដែលប្រែសេចក្ដីថា រីកិរិយានមស្ការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌[7] ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

## III- តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌

### ១- តួនាទីព្រះពុទ្ធសាសនាចំពោះបុគ្គល

ក្នុងរវាង៤៥ព្រះវស្សា ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទេសនាពន្យល់ ឬពាក្យប្រៀនប្រដៅរបស់ព្រះអង្គមានច្រើនណាស់ ក៏ប៉ុន្តែគោលដៅនៃការប្រៀនប្រដៅនេះ បើបង្រួមមកដោយសង្ខេបមាន៣យ៉ាងគឺ ៖

ទី១- **សព្វបាបស្ស អករណំ** : កិរិយាមិនធ្វើនូវអំពើបាបទាំងឡាយ គឺវៀរចាកការប្រព្រឹត្តអំពើអាក្រក់ អំពើទុច្ចរិត ទាំងកាយ វាចា និងចិត្ត។

ទី២- **កុសលស្សូបសម្បទា** : កិរិយាធ្វើអំពើល្អ ជាកុសលប្រកបដោយសុចរិត ខំសាងកុសលដោយធ្វើទាន និងរក្សាសីល។

ទី៣- **សចិត្តបរិយោទបនំ** : ឱ្យជុសខាត់ចិត្តរបស់ខ្លួនឱ្យស្អាតផូរផង់ ប្រាសចាកសៅហ្មង មានលោភៈ ទោសៈ មោហៈ ជាដើម។

តាមរយៈគោលទាំងបីខាងលើនេះ ព្រះពុទ្ធសាសនាជាកម្លាំងចលករក្នុងជំរុញសីលធម៌ និងចរិយាធម៌បុគ្គលម្នាក់ៗ សីលធម៌ និងចរិយាធម៌ក្នុងគ្រួសារ និងចំពោះសង្គមជាតិ។ ផ្ដើមចេញពីការប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា ពុទ្ធសាសនិកអាចទទួលបាននូវការអប់រំផ្លូវចិត្តជាច្រើន ព្រោះព្រះធម៌ប្រៀបបាននឹងឱសថព្យាបាលផ្លូវចិត្តដ៏ស័ក្តិសិទ្ធ។ សាសនាព្រះពុទ្ធជួយឃុំគ្រងការប្រព្រឹត្តបាបកម្មរបស់មនុស្ស ធ្វើឱ្យមនុស្សមានសេចក្តីសុខស្ងប់ខាងផ្លូវចិត្ត។ បើកាលណាផ្លូវចិត្តរឹងមាំ សុខភាពផ្លូវកាយក៏មានភាពល្អប្រសើរ។ ព្រះពុទ្ធសាសនាជួយបណ្ដុះឧបនិស្ស័យមនុស្សទៅរកវប្បធម៌អហិង្សា ឬសន្តិវិធី មានការតស៊ូព្យាយាមធ្វើអំពើល្អ លះបង់ការបៀតបៀនគ្នា ចេះបរិច្ចាគទាន ប្រកាន់ចិត្តសុចរិតទៀងត្រង់ ចំពោះខ្លួនឯង និងអ្នកដទៃ ចេះខ្មាស និងខ្លាចអំពើបាប រស់នៅដោយប្រកាន់នូវមេត្តាធម៌។

### ១.១- ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌បុគ្គល

#### ១.១.១- សីលប្រាំ ឬនិច្ចសីល

អ្វីដែលពុទ្ធបរិស័ទក៏ដូចជាមហាជនទូទៅបានជ្រួបជ្រាបក្នុងសន្តានចិត្ត និងអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃនោះគឺ "សីលប្រាំ ឬនិច្ចសីល"។ សីលប្រាំ ឬនិច្ចសីលនេះជាសិក្ខាបទដ៏សាមញ្ញមួយសម្រាប់ហ្វឹកហាត់ចិត្តគំនិតមនុស្សឱ្យស្គាល់អំពើល្អ វៀរចាកកិរិយាមិនគប្បីទាំងឡាយ ដើម្បីសន្សំគ្រាប់ពូជអំពើល្អ ហើយញុាំងជីវិតទៅរកសេចក្តីសុខទាំងពួង។ សីលប្រាំជាមហាទានដ៏វិសេសថ្លៃថ្លា ព្រោះជាអំណោយផ្តល់ឱ្យសព្វសត្វទាំងអស់នូវការរស់ ឱ្យនូវទ្រព្យសម្បត្តិ ឱ្យនៅសេចក្ដីសុខ ឱ្យនូវសេរីភាព និងសិទ្ធិទាំងឡាយ។

---

[7] *ញេយ្យធម៌ (ន.) ធម៌ដែលអ្នកប្រាជ្ញគួរដឹង។*

**សីលទីមួយគឺ បាណាតិបាតា** មានន័យថា កិរិយាវៀរចាកការសម្លាប់ជីវិតសត្វ។ ក្នុងន័យនេះ គឺអប់រំមនុស្សមិនឱ្យតាំងចេតនា មិនធ្វើឱ្យជីវិតសត្វវិនាសបង់ដោយឧបាយផ្សេងៗ។ សត្វទាំងឡាយស្រឡាញ់ជីវិតចង់រស់ ខ្លាចស្លាប់។ សូម្បីចំពោះច្បាប់នៃអង្គការសហប្រជាជាតិសព្វថ្ងៃ ក៏សូមឱ្យពិភពលោកគោរពសិទ្ធិមនុស្ស[8] ពោលគឺការវៀរចាកការកាប់សម្លាប់មនុស្សនេះឯង។ ព្រះពុទ្ធសាសនាមិនត្រឹមតែប្រដៅមនុស្សឱ្យគោរពសិទ្ធិមនុស្សនោះទេ តែថែមទាំងបានអប់រំមនុស្សឱ្យមនុស្សចិត្តមេត្តាធម៌ គោរពសិទ្ធិរស់នៅរបស់សត្វថែមទៀត។ មនុស្ស និងសត្វត្រូវតែមានសិទ្ធិរស់នៅលើផែនដីនេះដូចគ្នាដោយពុំមានការគាបសង្កត់។ ការមិនបៀតបៀនជីវិតសត្វ មានន័យថា យើងព្រមឱ្យអភ័យ យើងមិនសម្លាប់សត្វ គឺស្មើនឹងយើងឱ្យរបស់ដ៏វិសេសថ្លៃថ្លាខ្ពង់ខ្ពស់ដល់សត្វ គឺឱ្យអាយុវែងដល់ពួកគេ។ ការឱ្យការរស់រានមានជីវិតដល់សត្វ បានសេចក្ដីថា យើងសម្បូរការរស់(សម្បូរអាយុ)។ ការដែលយើងសម្បូរហូរហៀរ ទើបយើងឱ្យអ្នកដទៃបាន។ ដូច្នេះបុគ្គលមានឈ្មោះថា ជាជនសន្សំពូជអាយុវែង ជាអ្នកមិនមានរោគឱ្យខ្លួន ទាំងបច្ចុប្បន្នកាល ទាំងជាតិមុខ។ ផ្ទុយមកវិញបើយើងសម្លាប់ជីវិតគេ ព្រោះមកពីយើងខ្វះខាតជីវិត។ បុគ្គលនោះស្ថិតក្នុងពូជជននៃអ្នកអាយុខ្លី ព្រោះបានសន្សំពូជអាយុខ្លីទុកសម្រាប់ខ្លួន។ បើទោះជារួចខ្លួនក្នុងបច្ចុប្បន្នជាតិ ក៏ជាប់ទោសក្នុងអនាគតជាតិដែរ ព្រោះវាជាផលនៃហេតុ។ ដូច្នេះ ការឱ្យភាពរស់រានមានជីវិតដល់សព្វសត្វ គឺបានដល់ការសន្សំគ្រាប់ពូជជាអ្នកសម្បូរជីវិត ជាអ្នកមានអាយុវែង មានពណ៌សម្បុរល្អ មិនមានរោគ ជាអ្នកសម្បូរការជួបជុំ តែមិនសម្បូរការព្រាត់ប្រាស់ឡើយ។ ជារួម ការគោរពជីវិតអ្នកដទៃ ជាអំពើដ៏គប្បីឆ្លុះបញ្ចាំងពីការគោរពសិទ្ធិមនុស្ស។ បុគ្គលគោរពជីវិតអ្នកដទៃមានឈ្មោះថា ជាអរិយបុគ្គលដ៏ប្រសើរ។

**សីលទីពីរគឺ អទិន្នាទាន** មានន័យថា កិរិយាវៀរចាកការលួចទ្រព្យអ្នកដទៃ មិនតាំងចេតនា មិនកាន់យកនូវទ្រព្យអ្នកដទៃដែលគេមិនបានឱ្យដោយកាយ ឬវាចា។ ការមិនលួចទ្រព្យអ្នកដទៃ បុគ្គលនោះឈ្មោះថា ជាបុគ្គលសម្បូរដោយទ្រព្យ។ ការមិនលួចទ្រព្យអ្នកដទៃ គឺមិនចាំបាច់ទ្រព្យមានតម្លៃទេ សូម្បីតែរបស់កំប៉ិកកំប៉ុកដូចជា ចេកមួយផ្លែ ម្ទេសមួយគ្រាប់ក៏ចាត់ទុកជាអំពើខុសឆ្គង។ ការណ៍នេះ ព្រោះសម្មាសម្ពុទ្ធបានបញ្ញត្តិឡើង ដើម្បីជាទម្លាប់ល្អ និងជាសីលធម៌ល្អខ្ពង់ខ្ពស់របស់មនុស្ស។ មនុស្សរស់នៅក្នុងសង្គមអាចមានសេចក្ដីសុខស្ងប់ ប្រាសចាកការភ័យព្រួយទាំងឡាយពីការបាត់បង់ទ្រព្យ ដោយសារតែសង្គមបរិបូណ៌ដោយមនុស្សល្អ ជាមនុស្សមានសីល។ តាមតថភាពសង្គម បុគ្គលដែលមានលួច ឆក់ ប្លន់ ទ្រព្យអ្នកដទៃ រមែងមានឈ្មោះថា ជាចោរ។ ចោរនោះមានឈ្មោះថាផ្ដល់សេចក្ដីទុក្ខដល់អ្នកដទៃ អំពើនោះជាអំពើខុសច្បាប់ មិនយូរមិនឆាប់ គេចមិនផុតពីសំណាញ់ច្បាប់ឡើយ។ បុគ្គលនោះរមែងត្រូវផ្ដន្ទាទោស ត្រូវជាប់គុក ឬមួយត្រូវគេវាយប្រហារស្លាប់នៅនឹងកន្លែងតែម្ដង។ តាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៥៦បានចែងថា៖ *"អំពើលួចត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ៣(បី)ឆ្នាំនិងពិន័យជាប្រាក់ពី១.០០០.០០០*

[8] *សូមមើល កម្រងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សសហប្រជាជាតិចំពោះព្រះរាជាណាចក្រកម្ពុជា, ការិយាល័យឧត្ដមស្នងការកម្ពុជា, ឆ្នាំ២០១៤*

*(មួយលាន)រៀល*[9] ។ ហេតុនេះ ការរកស៊ីដោយសុចរិត មិនលួច ឆក់ ប្លន់ នោះសង្គមជាតិនឹងមានសេចក្ដីសុខសាន្ត និងវឌ្ឍនភាពសង្គម។ ក្នុងន័យនេះហើយ ទើបព្រះបរមគ្រូបញ្ញត្តិទុកមកដោយហាមប្រាមមិនឱ្យប៉ះពាល់ទ្រព្យសម្បត្តិអ្នកដទៃឡើយ។ នរជនណាដែលប្រតិបត្តិតាម នរជននោះនឹងទទួលបានសេចក្ដីសុខ។

**សីលទីបីគឺ កាមេសុមិច្ឆាចារ** មានន័យថា កិរិយាវៀរចាកការប្រព្រឹត្តខុសក្នុងផ្លូវកាមទាំងឡាយ។ ការលួចមានសហាយស្មន់ ប្រពន្ធ កូន ប្ដី របស់គេ។ ទង្វើនេះពុំផ្ដល់ផលល្អដល់បុគ្គលអ្នកប្រព្រឹត្តឡើយ។ ក្នុងសង្គមនាពេលបច្ចុប្បន្ន ជនដែលបានប្រព្រឹត្តអំពើបៀតបៀនលើប្រពន្ធ កូន ប្ដី អ្នកដទៃ រមែងនាំមកនូវភាពអាម៉ាស់យ៉ាងក្រាស់ក្រែ និងខូចកិត្តិយស បាត់បង់សេចក្ដីថ្លៃថ្នូរជាមនុស្ស ហើយច្បាប់ត្រូវផ្ដន្ទាទោស ឬបង្កជាគំនុំសងសឹកបាញ់បោះ កាប់សម្លាប់ជាដើម។ ជាងនេះទៅទៀត អ្នកដែលចូលចិត្តលេងល្បែងស្នេហាមិនស្មោះត្រង់ តែងប្រឈមមុខនឹងជំងឺកាមរោគ មានជំងឺអេដស៍ជាដើម។ ការមិនស្មោះត្រង់នឹងភរិយា ឬដៃគូស្នេហា រមែងនាំមកនូវទុក្ខទោសច្រើនអនេក មានការខាតបង់ទ្រព្យ ខាតបង់ពេលវេលា និងនាំរោគកាចសាហាវចូលផ្ទះចម្លងដល់ប្រពន្ធកូន។ ក្នុងរបាយការណ៍របស់អង្គការ UNAIDS ឆ្នាំ២០២២ អង្គការនេះបានអះអាងថា *នៅកម្ពុជាជារៀងរាល់ថ្ងៃ មនុស្សចំនួន៣នាក់បានឆ្លងនូវមេរោគអេដស៍* [10] ។ ដោយមើលឃើញពីទុក្ខទោសកើតចេញអំពីភាពមិនស្មោះត្រង់ក្នុងផ្លូវកាម ទើបព្រះសម្មាសម្ពុទ្ធទ្រង់ហាមមិនឱ្យប្រព្រឹត្តខុសក្នុងផ្លូវកាម។ ដូច្នេះ សីលទីបីនេះ មាននាទីសំខាន់ក្នុងការចូលរួមលើកកម្ពស់សីលធម៌បុគ្គលឱ្យប្រាសចាកពីភាពអបាយមុខក្នុងផ្លូវកាម ដើម្បីកសាងសីលធម៌សង្គម ឈានឈ្មោះទៅរកភាពសុខដុមរមនា ផ្ដល់ភាពថ្លៃថ្នូរដល់សង្គមជាតិ វិបុលសុខដល់ខ្លួនឯង គ្រួសារ និងអ្នកដទៃផងដែរ។

**សីលទីបួនគឺ មុសាវាទ** មានន័យថា កិរិយាវៀរចាកការកុហក ឬការផ្ដល់ការមិនពិតដល់អ្នកស្ដាប់។ មុសាវាទអាចនាំឱ្យអ្នកដទៃស្លាប់ នាំឱ្យវិនាសទ្រព្យ និងនាំមកនូវសេចក្ដីទុក្ខលំបាកផ្សេងៗជាច្រើន។ កាលណាអ្នកស្ដាប់ដឹងថា យើងនិយាយមិនពិត គេចាត់ទុកបុគ្គលនោះជាមនុស្សឥតបានការ ហើយតទៅថ្ងៃមុខទៀត ទោះបុគ្គលនិយាយពាក្យពិត ក៏គេលែងជឿ។ ការនិយាយកុហកដល់អ្នកដទៃ គឺការផ្ដល់ឱ្យអ្នកដទៃនូវភាពមិនពិត ដោយបុគ្គលសម្បូរនូវការមិនទៀងត្រង់ក្នុងសន្ដានចិត្ត។ អ្នកកុហកបោកប្រាស់ត្រូវបានគេលែងរាប់អាន អស់លក្ខណ៍ ឬទទួលផលតបស្នងនាថ្ងៃណាមួយ។ ដោយឃើញពីផលបែបនេះ ទើបព្រះបរមគ្រូនៃយើងបានបង្ហាញផ្លូវដល់បរិស័ទទាំងឡាយ ឱ្យពោលតែពាក្យសច្ចៈ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងថា "***សច្ចំ ហវេ សាធុតរំ រសានំ***" ដែលប្រែសេចក្ដីថា រសនៃសច្ចធម៌ប្រសើរជាងរសទាំងពួង។ ព្រះពុទ្ធទ្រង់បង្ហាញផ្លូវដល់មនុស្សឱ្យចេះនិយាយស្ដីបានត្រឹមត្រូវ គោរពពាក្យសត្យ ប្រកាន់ក្រមសីលធម៌ល្អក្នុងការនិយាយស្ដី។ អ្នកពោលពាក្យសច្ចៈរមែងបានសុខចម្រើន មានកេរ្តិ៍ឈ្មោះ មានកិត្តិយស មានគេគោរពស្រឡាញ់រាប់អាន និងសេចក្ដីសរសើរ ញ៉ាំងជីវិតឱ្យចាកឆ្ងាយពីអំពើវិនាសទាំងពួង។

---

[9] *ក្រសួងយុត្តិធម៌, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០១០, ទំ.១១៦*

[10] *វិទ្យុបារាំងអន្តរជាតិ, UN នៅកម្ពុជាអំពាវនាវយុវវ័យប្រុងប្រយ័ត្ន និងការពារខ្លួនពីការឆ្លងជំងឺអេដស៍, ចុះផ្សាយថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣*

**សីលទីប្រាំគឺ សុរាមេរ័យ** មានន័យថា កិរិយាវៀរចាកការសេពគ្រឿងស្រវឹងទាំងពួង។ ការទទួលទានសុរា ឬមេរ័យនាំឱ្យស្រវឹង។ ការស្រវឹងនាំមនុស្សបាត់បង់សតិសម្បជញ្ញៈ ហើយការបាត់សតិនេះញ៉ាំឱ្យមនុស្សមានសេចក្តីធ្វេសប្រហែស អាចក្លាហានខុសទំនង និងប្រព្រឹត្តអំពើឃោរឃៅផ្សេងៗបាន។ អ្នកស្រវឹងស្រាមែងហ៊ានធ្វើអំពើអាក្រក់ផ្សេងៗដោយពុំគិតពីផលលំបាក គឺសេចក្តីទុក្ខធ្លាក់មកលើខ្លួន និងគ្រួសារឡើយ។ម្យ៉ាងទៀតស្រាបណ្តាលឱ្យមានជំងឺក្រិនថ្លើម ឈឺក្រពះ ដាច់សរសៃឈាមខួរក្បាល(សម្ពាធឈាមឡើងខ្ពស់) ពោលគឺស្រាធ្វើឱ្យមនុស្សអាយុខ្លី។ ក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២-២០២៣ កាលពីថ្ងៃអង្គារ ទី២៣ ខែមករា ឆ្នាំ២០២៣កន្លងទៅ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានមានប្រសាសន៍ណែនាំថា "*សូមឱ្យសារព័ត៌មានចូលរួមផ្សព្វផ្សាយ អប់រំឱ្យប្រជាជនយល់ដឹងអំពីផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង... បើកបរ...*"។ ក្នុងនិក្ខេបបទរបស់និស្សិតវេជ្ជសាស្ត្រឯកទេសប្រព័ន្ធរំលាយអាហារ និងរិកលវិទ្យានៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលកាលពីចុងឆ្នាំ២០២០ និងដើមឆ្នាំ២០២១ បានបង្ហាញថា ៖ "*ទី១ អ្នកជំងឺក្រិនថ្លើមជាបុរសដែលញៀនស្រា។ ទី២ អ្នកជំងឺកើតចិត្តវិកល(ចិត្តវិបល្លាស) ភាគច្រើនជាអ្នកសេពស្រា និងគ្រឿងញៀន*"[11]។ នេះសបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ពីទោសនៃសុរា ដែលបុគ្គលគួរចៀសវាង ព្រោះថាស្រាបានសម្លាប់មនុស្សជាច្រើននាក់ជារៀងរាល់ថ្ងៃ និងបង្កផលប៉ះពាល់ជាច្រើនទៀតដល់សង្គម។

បើតាមទ្រឹស្តីព្រះពុទ្ធសាសនា ទោសនៃការសេពសុរាមាន៦យ៉ាង[12] គឺ ទី១ វិនាសទ្រព្យ, ទី២ បង្កើតជម្លោះ, ទី៣ វិនាសសុខភាព(ឆាប់ចាស់មុនអាយុ), ទី៤ ទម្លាយអាថ៌កំបាំង និងបើកកេរ្តិ៍ខ្មាសដោយឥតអៀនខ្មាស, ទី៥ ខូចកេរ្តិ៍ឈ្មោះ និងទី៦ ធ្វើឱ្យប្រាជ្ញា ហើយបន្ទាប់ពីស្លាប់ធ្លាក់ចុះនរក។ សេសសល់ផលកម្មពីនរកមកកើតជាមនុស្សវិញ ក្លាយជាមនុស្សល្ងង់ខ្លៅ មនុស្សវិកលចរិតឆ្កួតលីលាផ្តេសផ្តាស។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបពីទោស ពីសេចក្តីវិនាសនៃស្រានេះឯង ទើបព្រះអង្គបញ្ញត្តិឱ្យវៀរចាកការផឹកទឹកស្រវឹង គឺស្រានេះឯងនៅក្នុងសិក្ខាបទទី៥នៃសីលប្រាំ។ ការមិនសេពទឹកស្រវឹងរមែងញ៉ាំងឱ្យបុគ្គលទទួលបាននូវភាពសុខកាយសប្បាយចិត្ត ចម្រើនទ្រព្យ មិនភ្លាត់ភ្លាំងស្មារតី មិនធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ ហើយមានសេចក្តីថ្លៃថ្នូរជាដរាប។

ជារួមមក សីលប្រាំនេះជាគោលមូលដ្ឋានដំបូងបង្អស់សម្រាប់អប់រំមនុស្សឱ្យមានសណ្តាប់ធ្នាប់ល្អ។ ប្រសិនបើយើងធ្វើការពិចារណាតាមហេតុផលពិត យើងឃើញថា សីលប្រាំជាកាតព្វកិច្ចរបស់មនុស្ស ព្រោះមនុស្សយើងរស់នៅក្នុងសង្គមរមែងស្អប់ខ្ពើមការឈ្លោះទាស់ទែង កាប់សម្លាប់ លួចឆក់ប្លន់ កេងប្រវ័ញ្ចទ្រព្យគ្នា លួចប្រពន្ធកូនគ្នា វក់វីនឹងការសេពសុរា។ល។ ដូច្នេះ សីលប្រាំ ឬនិច្ចសីលជាសិក្ខាបទដែលជួយរំឭកមនុស្សជាមាគ៌ាដ៏បវរដឹកនាំមនុស្សឱ្យអនុវត្តខ្លួនបានត្រឹមត្រូវ ដើម្បីខ្លួនឯង គ្រួសារ និងសង្គមជាតិទទួលបាននូវសេចក្តីសុខ សុវត្ថិភាព សេចក្តីថ្លៃថ្នូរ មានសណ្តាប់ធ្នាប់ និងសីលធម៌ ចរិយាធម៌ល្អប្រពៃ។

---

[11] *វេជ្ជបណ្ឌិត ហង់ ច័ន្ទវរៈ, សីលរតនៈ, បោះពុម្ពលើកទី៣ ឆ្នាំ២០២២, ទំ.៨០*

[12] *បិដកលេខ៥៨, ទំ.៣៦*

### ១.១.២- កុសលកម្មបថ១០ប្រការ

ព្រះពុទ្ធមានពុទ្ធដីកាថា "មនុស្សទាំងឡាយគួរកុំប្រព្រឹត្តអំពើណាដែលមិនគប្បីដល់អ្នកដទៃឱ្យសោះ បើយើងមិនចង់ឱ្យគេប្រព្រឹត្តអំពើនោះមកលើខ្លួនយើងវិញ"។ អាស្រ័យហេតុនេះ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងបានណែនាំឱ្យមនុស្សប្រព្រឹត្តអំពើល្អ អំពើសុចរិត ពោលគឺប្រកាន់យកសុចរិតធម៌១០យ៉ាង ឬកុសលកម្មបថ១០។ អំពើល្អ១០យ៉ាងនេះ ជាគោលការណ៍ ឬឫសគល់ក្នុងការស្វែងរកសុខសន្តិភាព សុវត្ថិភាព សេចក្ដីថ្លៃថ្នូរក្នុងការរស់នៅសម្រាប់បុគ្គលខ្លួនឯងផង គ្រួសារផង និងសង្គមជាតិផង។ កុសលកម្មបថទាំង១០ នោះ រួមមាន ៖

#### ក- កាយសុចរិត៣ប្រការ

កាយសុចរិត៣ មានន័យថា ការប្រព្រឹត្តល្អដោយកាយ៣។ ទី១ គឺការវៀរចាកការកាប់សម្លាប់ជីវិតមនុស្ស សត្វមានជីវិត។ គេមិនត្រូវបៀតបៀន ឬធ្វើទុក្ខបុកម្នេញដល់ជីវិតអ្នកដទៃដោយការបាញ់បោះ កាប់ប្រហារ ចាក់ ធ្វើឱ្យជីវិតអ្នកដទៃត្រូវសាបសូន្យឡើយ។ ទី២ គឺការមិនគេងបន្លំយកទ្រព្យសម្បត្តិអ្នកដទៃ ឬក៏ការលួច ឆក់ ប្លន់ របស់ទ្រព្យអ្នកដទៃ។ ទី៣ គឺការមិនប្រព្រឹត្តខុសក្នុងផ្លូវកាមទាំងឡាយ មិនបៀតបៀនទៅលើប្រពន្ធ កូន ប្ដីអ្នកដទៃ ដែលធ្វើឱ្យប៉ះពាល់ដល់ជីវិតរស់នៅរបស់ខ្លួន។ កាយសុចរិត៣នេះមានចែងក្នុងសីលប្រាំ ឬនិច្ចសីល ដែលជាគោលការណ៍ដែលជួយអប់រំ ហ្វឹកហាត់ ចិត្តគំនិតបុគ្គលឱ្យក្លាយជាមនុស្សល្អប្រាសចាកអំពើអកុសលនានាធ្វើឱ្យប៉ះពាលគុណភាពជីវិត។

#### ខ- វចីសុចរិត៤ប្រការ

វចីសុចរិត៤ មានន័យថា ការប្រព្រឹត្តល្អដោយវាចា៤។ វចីសុចរិត៤នេះ ជួយអប់រំសីលធម៌មនុស្សលើការនិយាយស្ដីឱ្យមានសណ្ដាប់ធ្នាប់ បានត្រឹមត្រូវ មានសច្ចវាចា ដែលជាកត្តានាំមនុស្សឱ្យមានតម្លៃថ្លៃថ្នូរ មានវប្បធម៌ខ្ពង់ខ្ពស់ជាងសត្វតិរច្ឆាន។ ទី១ គឺការមិននិយាយឆបោកអ្នកដទៃ(មុសាវាទ), ទី២ មិនញុះញង់បំបែកបំបាក់អ្នកដទៃ, ទី៣ មិនពោលពាក្យទ្រគោះបោះបោក ឬជេរប្រទេចផ្ដាសាអ្នកដទៃ និងចុងក្រោយគឺ ការមិនពោលពាក្យរាយមាយឥតប្រយោជន៍។ ជាការពិត ក្នុងជីវភាពរស់នៅបច្ចុប្បន្ន មនុស្សតែងឱ្យតម្លៃលើពាក្យសម្ដីភាសាទំនាក់ទំនងគ្នាខ្លាំងណាស់។ ការនិយាយពាក្យមិនពិត កុហកបោកប្រាស់ ពោលពាក្យមិនពីរោះពិសារាយមាយ រមែងក្លាយជាទីសម្អប់នៃមហាជន ឬជនទូទៅ។ ព្រះសម្មាសម្ពុទ្ធបានបញ្ញត្តិឱ្យមនុស្សនិយាយត្រូវ (សម្មាវាចា)។ ការនិយាយត្រូវ ជាផ្លូវនាំមនុស្សឱ្យចេះមានការប្រុងប្រយ័ត្ន ចៀសវាងការជេរប្រទេសផ្ដាសា នាំឱ្យមានការប៉ះពាល់ដល់បុគ្គលដទៃ។ ក្នុងការនិយាយស្ដីនេះ ក៏យើងឃើញមានសុភាសិតខ្មែរពោលថា "*អណ្ដាតជាអាទិ៍កន្លង បានសុខទុក្ខផងក៏ព្រោះអណ្ដាត*" ជាដើម។

#### គ- មនោសុចរិត៣ប្រការ

មនោសុចរិត៣ មានន័យថាការប្រកាន់ខ្ជាប់នូវសន្តានចិត្តល្អ៣យ៉ាងគឺ ទី១ ការមិនមានចិត្តរំពៃចង់បានទ្រព្យអ្នកដទៃ, ទី២ ការមិនមានចិត្តគំនុំគុំកួន ឬព្យាបាទអ្នកដទៃ និងទី៣ មានគំនិតយល់ឃើញត្រូវពិតតាមច្បាប់របស់សង្គម(សម្មាទិដ្ឋិ)។

មនុស្សដែលប្រកាន់នូវសុចរិតធម៌ គោរពតាមគោលការណ៍នៃកុសលកម្មបថ១០នេះ រមែងរស់នៅមានសុវត្ថិភាព សុភមង្គល និងសេចក្ដីថ្លៃថ្នូរ។ គេពុំទទួលនូវការត្មះតិះដៀលពីអ្នកផងទាំងពួង គ្មានការព្យាបាទ សងសឹក ញ៉ាំងជីវិតឱ្យមានសុភមង្គលក្នុងគ្រួសារ សហគមន៍ និងសង្គមមានសុខសន្តិភាព។

**១.១.៣- អរិយសច្ចៈ**

តាមវចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ពាក្យ អរិយសច្ចៈ មានន័យថា *សេចក្ដីពិតរបស់អរិយបុគ្គល, សេចក្ដីពិតឥតមានល្បៀង* [13] ។ ព្រះពុទ្ធទស្សនវិទូនៃយើង បានពិចារណាឃើញមាន៤ប្រការ គឺ ទុក្ខអរិយសច្ចៈ សមុទយអរិយសច្ចៈ និរោធអរិយសច្ចៈ និងមគ្គអរិយសច្ចៈ។ ទ្រឹស្ដីនៃព្រះពុទ្ធសាសនាបានពន្យល់មនុស្សឱ្យឃើញពីភាពពិតនៃជីវិតដែលមិនអាចប្រកែកបាន និងបង្ហាញផ្លូវមនុស្សទៅរកទីបរមសុខ។ ទស្សនវិជ្ជាពុទ្ធសាសនាមានគោលដៅស្វែងយល់រកហេតុផលនៃសេចក្ដីសុខ និងសេចក្ដីទុក្ខ។

**ក- ទុក្ខអរិយសច្ចៈ** គឺទុក្ខជាសេចក្ដីពិតដែលកើតមានដល់មនុស្ស សត្វគ្រប់ៗរូប ហើយពុំអាចចៀសផុតបានឡើយ គ្រាន់តែអ្នកខ្លះមានទុក្ខតិច អ្នកខ្លះមានទុក្ខច្រើន។ ទុក្ខអរិយសច្ចៈមាន ជាតិទុក្ខ(ទុក្ខព្រោះមានកំណើត) ព្យាធិទុក្ខ(ទុក្ខព្រោះឈឺ) ជរាទុក្ខ(ទុក្ខព្រោះចាស់) និងមរណទុក្ខ(ទុក្ខព្រោះស្លាប់)។

**ខ- សមុទយអរិយសច្ចៈ** គឺទុក្ខជាសេចក្ដីពិតដែលកើតមកអំពីហេតុ ឬឫសគល់ពិត។ ហេតុដែលនាំមានទុក្ខមានពីរធំៗ គឺអវិជ្ជា និងតណ្ហា។ អវិជ្ជាគឺសេចក្ដីល្ងង់ខ្លៅ មិនដឹង មិនយល់នូវហេតុនាំឱ្យមានទុក្ខ។ អវិជ្ជានេះ នាំឱ្យកើតមានតណ្ហា។ តណ្ហាគឺជាសេចក្ដីស្រេកឃ្លាន សេចក្ដីប្រាថ្នា សេចក្ដីលោភ ចង់មានចង់បានអ្វីៗ មិនចេះឆ្អែត មិនចេះចប់។ តណ្ហានេះជាហេតុនាំឱ្យមនុស្សមានទុក្ខ។

**គ- សមុទយអរិយសច្ចៈ** គឺការរំលត់ទុក្ខជាសេចក្ដីពិត។ កន្លែងរំលត់ទុក្ខ គឺព្រះនិព្វាន។ ដើម្បីរំលត់ទុក្ខ គេត្រូវបំបាត់អវិជ្ជា រំលាយតណ្ហា។ កាលណាគេរំលើងទាំងពីរយ៉ាងនេះបានអស់ហើយ ទុក្ខនានាក៏ពុំអាចកើតមានទៀតឡើយ។

**ឃ- មគ្គអរិយសច្ចៈ** គឺផ្លូវរំលត់ទុក្ខ ដែលជាសេចក្ដីពិត។ ព្រះពុទ្ធបរមគ្រូនៃយើង បានណែនាំមនុស្សឱ្យប្រកាន់ផ្លូវកណ្ដាល(មជ្ឈិមប្បដិបទា) ហើយប្រតិបត្តិនូវមគ្គ៨យ៉ាង ហៅថា "អដ្ឋង្គិកមគ្គ" ដែលមានដូចជា ៖

**សម្មាទិដ្ឋិ** : ការយល់ឃើញត្រូវ គឺយល់ឃើញពិតនូវសភាវធម៌ទាំងពួង ឃើញតាមរយៈអរិយសច្ចៈទាំង៤ ហើយពេញចិត្ត និងប្រតិបត្តិតាមផ្លូវត្រូវ ដើម្បីលុបបំបាត់អវិជ្ជា និងតណ្ហា។

**សម្មាសង្កប្ប** : ការត្រិះរិះត្រូវ គឺត្រិះរិះក្នុងការមិនព្យាបាទ មិនបៀតបៀនចំពោះមនុស្ស សត្វទូទៅហើយការត្រិះរិះបានត្រឹមត្រូវនាំឱ្យជីវិតបានសុខ និងចំរើន។

**សម្មាវាចា** : ការវាចាត្រូវ គឺវៀរចាកវចីទុច្ចរិត៤ ដែលនាំឱ្យខ្លួនបានសេចក្ដីសុខ ពោលគឺនិយាយឱ្យត្រូវ ឱ្យមានសច្ចៈ សុចរិត។

[13] *ជួន ណាត, វចនានុក្រមខ្មែរ, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧, ទំ.១៦៨០*

**សម្មាកម្មន្ត** : ការងារត្រឹមត្រូវ គឺប្រកាន់ការប្រព្រឹត្តល្អដោយកាយ វៀរចាកទុច្ចរិត៣យ៉ាង គឺការសម្លាប់សត្វ ការលួចទ្រព្យអ្នកដទៃ និងប្រព្រឹត្តខុសក្នុងផ្លូវកាម។

**សម្មាអាជីវោ** : ការចិញ្ចឹមជីវិតត្រូវ គឺការវៀរចាកការចិញ្ចឹមជីវិតខុសគន្លងនៃភាពត្រឹមត្រូវ។

**សម្មាវាយាម** : ការព្យាយាមត្រូវ គឺការព្យាយាមធ្វើអំពើល្អ ជាកុសល មិនឱ្យមានបាប អកុសល។

**សម្មាសតិ** : ការរឭកនឹកឃើញត្រូវ គឺការដឹងខ្លួនជានិច្ច។

**សម្មាសមាធិ** : ការធ្វើសមាធិត្រឹមត្រូវ គឺតម្កល់ចិត្តមិនឱ្យរវើរវាយ អណ្តែតអណ្តូង ពោលគឺតាំងចិត្តឱ្យស៊ប់ជានិច្ចក្នុងអារម្មណ៍តែមួយ។

| | | | | | | | |
|---|---|---|---|---|---|---|---|
| សម្មាវាចា<br>សម្មាកម្មន្ត<br>សម្មាអាជីវៈ | សីល | សម្មាវាយាម<br>សម្មាសតិ<br>សម្មាសមាធិ | សមាធិ | សម្មាសង្កប្ប<br>សម្មាទិដ្ឋិ | បញ្ញា |

មគ្គទាំង៨នេះ បើបង្រួមមកមានបីគឺ "**សីល សមាធិ បញ្ញា**"។ សម្មាទិដ្ឋិ សម្មាសង្កប្ប ចាត់ជាបញ្ញាសិក្ខាការអប់រំខាងបញ្ញា(អភិវឌ្ឍបញ្ញា)។ ចំណែក សម្មាវាចា សម្មាកម្មន្ត សម្មាអាជីវោ ចាត់ជាសីលសិក្ខាអប់រំកាយវាចា ឱ្យមានសណ្តាប់ធ្នាប់ កុំឱ្យច្រឡើសបើស ច្រឡោងខាម មានសីលធម៌រស់នៅក្នុងសង្គមបានសុខចម្រើន(អភិវឌ្ឍកាយវាចា)។ រីឯ សម្មាវាយាម សម្មាសតិ សម្មាសមាធិ ចាត់ជាសមាធិសិក្ខាអប់រំផ្លូវចិត្ត (អភិវឌ្ឍចិត្ត) ឱ្យរួចផុតពីកិលេស គឺតណ្ហាលោភៈ ទោសៈ មោហៈ ដែលជាគ្រឿងសៅហ្មងនាំឱ្យបង្កនូវសង្ខារដែលជាហេតុនាំឱ្យជួបប្រទះគេចមិនផុតពីទុក្ខសោកគ្រប់បែបយ៉ាង។

ជារួមមកវិញ មគ្គទាំង៨នេះ ជាផ្លូវដ៏ប្រសើរ ព្រោះវាជាផែនទីចង្អុលទិសឱ្យអ្នកប្រតិបត្តិតាម អាចសម្រេចគោលដៅដ៏សំខាន់ក្នុងជីវិត ធ្វើឱ្យដល់នូវការអស់ទៅនៃតណ្ហា លោភៈ ទោសៈ មោហៈ ហើយទទួលបានសុខសន្តិភាពសម្រាប់ខ្លួនឯងផង សម្រាប់មនុស្សសត្វទាំងអស់ផង។

## ១.២- ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ចំពោះគ្រួសារ

### ១.២.១ ព្រហ្មវិហារធម៌មាតាបិតាចំពោះបុត្រធីតា

ព្រហ្មវិហារធម៌ ជាធម៌របស់ព្រះព្រហ្មដែលក្រាលចិត្តសន្ដោសប្រណី ចំពោះមនុស្សសត្វដោយគ្មានការរើសអើង។ ព្រហ្មវិហារធម៌ ជាធម៌ជាទីនៅរបស់ព្រះព្រហ្ម ឬជាធម៌ប្រតិបត្តិ ដើម្បីមនុស្សរស់នៅបានល្អប្រសើរដែលប្រជាជនគ្រប់ស្រទាប់វណ្ណៈ នឹងត្រូវប្រតិបត្តិ ដើម្បីសាមគ្គីភាព និងភាពសុខក្សេមក្សាន្តក្នុងគ្រួសារ និងសង្គម។

ប្រាសាទបាយ័នជាប្រាសាទដ៏ល្បីល្បាញមួយដែលមានរូបព្រហ្មមុខបួន ជាតំណាងព្រះភក្ត្រពោធិសត្វព្រះអវលោកេស្វរៈដែលជាព្រះពោធិសត្វនៃពុទ្ធសាសនាមហាយាន។ ព្រះភក្ត្រដែលបែរទៅកាន់ទិសទាំងបួនតំណាងព្រហ្មវិហារធម៌ទាំងបួន ដែលមាតាបិតាមានចំពោះបុត្រ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានចាត់ទុកមាតាបិតាជា "**ព្រះរស់**" ជាអ្នកមានគុណ ព្រោះលោកទាំងពីរមានព្រហ្មវិហារធម៌ចំពោះបុត្រធីតា។ ព្រហ្មវិហារធម៌របស់មាតាបិតា ជាធម៌ដ៏ប្រសើរបំផុត ព្រោះមាតាបិតាប្រកបទៅដោយ ៖

**មេត្តា** : ស្រឡាញ់ ប្រាថ្នាឱ្យកូនបានសុខ ពិសេសស្រឡាញ់តាំងពីដឹងថាខ្លួនមានផ្ទៃពោះ គឺធ្វើយ៉ាងណាមិនឱ្យខូចសុខភាពដល់កូនក្នុងផ្ទៃ។

**ករុណា**: សេចក្ដីអាណិតអាសូរគិតចង់ឱ្យកូនរួចពីទុក្ខ ចាប់តាំងពីប្រសូតមក ប្រុសក្ដី ស្រីក្ដី ល្អអាក្រក់យ៉ាងណាក៏ដោយក៏មាតាបិតាចិញ្ចឹមកូនឱ្យរស់រានមានជីវិត។

**មុទិតា** : សេចក្ដីត្រេកអរក្នុងវេលាដែលកូនបានសុខ ត្រេកអរតាំងពីកូនរៀននិយាយ ចេះសើច ហើយតែងសរសើរកូនគ្រប់ពេល។

**ឧបេក្ខា** : តាំងចិត្តជាកណ្ដាល។ មាតាបិតាតែងស្រឡាញ់កូនដោយស្មើៗគ្នា។

ព្រហ្មវិហារធម៌ទាំងបួននេះ ជាធម៌ដ៏ល្អវិសេសបំផុតក្នុងការកសាងសុភមង្គលក្នុងគ្រួសារ។ ដោយអំណាចនៃព្រហ្មវិហារធម៌ទាំងនេះ មាតាបិតាតែងខំព្យាយាមស្វែងរកទ្រព្យសម្បត្តិសម្រាប់ជួយឧបត្ថម្ភដល់បុត្រធីតា ទោះបីមានការហត់នឿយយ៉ាងណា ក៏នៅតែស្វះស្វែងសង្វាតឃ្មាតខ្មី។ លុះដល់កូនពេញវ័យកាលណា លោកទាំងពីររៀបចំគូស្រករឱ្យបានសមគួរ និងចែកទ្រព្យឱ្យកូនថែមទៀតផង។

មាតាបិតាត្រូវស្គាល់តួនាទី៥របស់ខ្លួន ចំពោះបុត្រធីតា [14] ៖

ទី១ ហាមឃាត់កូនចាកអំពើអាក្រក់គ្រប់យ៉ាង

ទី២ បង្រៀនកូនឱ្យប្រព្រឹត្តអំពើល្អ

ទី៣ បញ្ជូនកូនឱ្យសិក្សារៀនសូត្រ

ទី៤ រៀបចំទុកដាក់កូនឱ្យមានគូស្រករ

ទី៥ ចែកទ្រព្យសម្បត្តិដល់កូន។

មាតាបិតាជាមេគ្រួសារ និងជាអ្នកមានតួនាទីណែនាំអប់រំទូន្មានកូនឱ្យប្រព្រឹត្តនូវអំពើល្អ អំពើជាកុសល ចេះហាមឃាត់កូនក្នុងកាលដែលកូនធ្វើនូវអំពើបាបផ្សេងៗ បញ្ជូនកូនទៅសិក្សារៀនសូត្រ ក្រេបយកចំណេះ។ បន្ទាប់ពីបានចំណេះហើយ មាតាបិតាគប្បីចាត់ចែងឱ្យបានសមគួររៀបចំទុកដាក់កូនចៅឱ្យមានគូស្រករ និងចែកទ្រព្យឱ្យកូនតាមការគួរ។ ការដែលបានធ្វើបែបនេះហើយ គឺមានឈ្មោះថា "មាតាបិតាអនុគ្រោះបុត្រដោយស្ថាន៥យ៉ាង"។ កាតព្វកិច្ចនេះជាភារៈដែលក្នុងនាមជាឪពុកម្ដាយត្រូវបំពេញ ដើម្បីកសាងអនាគតកូនឱ្យភ្លឺស្វាង និងក្លាយជាមនុស្សមានភាពថ្លៃថ្នូរនៅក្នុងសង្គមជាតិ។

### ១.២.២- ភាពកតញ្ញូនៃបុត្រធីតាចំពោះមាតាបិតា

មាតាបិតាជាបុគ្គលមានឧបការគុណដល់បុត្រធីតាដោយច្រើនក្រៃលែង។ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងថា "ទុកដូចជាព្រហ្ម" សមដូចបាលីថា "***ឧភោបេតេ ព្រហ្មា បុព្វទេវា បុញ្ញាចរិយា អាហុនេយ្យាតិ ច វុច្ចតិ***" ដែលប្រែថា មាតាបិតាទាំងពីរនាក់នេះព្រះសម្មាសម្ពុទ្ធពោលថា ជាព្រហ្ម១ ជាបុព្វទេព១ ជាបុញ្ញាចារ្យ១ ជាអហុនេយ្យៈ១ [15] ។ ពាក្យថា *ព្រហ្ម* សំដៅយកមាតាបិតាដែលមានព្រហ្មវិហារធម៌ក្នុងសន្ដានចិត្ត ហើយ

[14] *វិនយប្បញ្ញោ ដុង សុភឿន, សិង្គាលកសូត្រអរិយវិន័យធម៌សម្រាប់ការរស់នៅប្រចាំថ្ងៃក្នុងសង្គម, ឆ្នាំ២០១៣, ទំ.៦៥*

[15] *ព្រះឧបាលិវង្ស សូរ ហាយ, កតញ្ញូកតវេទិកថា, ឆ្នាំ១៩៥៧, ទំ.៤-៥*

សង្គ្រោះទំនុកបម្រុងដល់បុត្រធីតាតាមកម្លាំងនៃព្រហ្មវិហារធម៌៤ប្រការគឺមេត្តា ករុណា មុទិតា និងឧបេក្ខា។ ចំណែក *បុព្វទេព* ដោយមាតាបិតាបានចិញ្ចឹមបីបាច់ថែរក្សាកូនផ្ទាល់មុនដំបូងគេបង្អស់ជាងអ្នកឯទៀត។ ដោយហេតុនេះ មាតាបិតាមានឈ្មោះថា ជាទេវតារបស់កូនប្រុសស្រី។ រីឯ *បុព្វាចារ្យ* ដោយមាតាបិតាបានបង្ហាត់បង្រៀនទារក ទារិកា តាំងពីទើបនឹងកើតមក។ ចំណែកចុងក្រោយគឺ *អាហុនេយ្យៈ* ដោយមាតាបិតាមានឋានៈជាអ្នកទទួលសក្ការបូជាពីកូនប្រុសស្រី ហើយញ៉ាំងបុណ្យកុសលឱ្យកើតមានដល់បុត្រធីតាប្រុសស្រីទាំងឡាយ។

ដោយឈរលើចំណុចនេះ ព្រះសម្មាសម្ពុទ្ធបានទូន្មានបុត្រធីតាទាំងឡាយឱ្យមានកតវេទិតាដោយគោរពចំពោះមាតាបិតា ដោយបំពេញតួនាទី៥យ៉ាងជាការតបស្នងគឺ ៖

**ទី១ ចិញ្ចឹមមាតាបិតា** គឺជូនភោជនាហារ សំពត់អាវដែលត្រូវប្រើប្រាស់ ផ្ទះសម្រាប់ជ្រកកោន គក់ប្របាច់ ផ្ងូតទឹក គ្រប់ពេលវេលា។

**ទី២ ធ្វើកិច្ចជំនួសមាតា** គឺករណីយកិច្ចគ្រប់យ៉ាងក្នុងទីជិតក្តី ឆ្ងាយក្តី ដែលមាតាបិតាមានវ័យចាស់ជរា មិនអាចធ្វើទៅបាន ឬធ្វើបានដោយលំបាក។

**ទី៣ តម្កល់វង្សត្រកូលមាតាបិតា** គឺជួយបំពេញប្រយោជន៍ ជួយណែនាំពន្យល់បងប្អូនញាតិមិត្តសាច់សាលោហិតក្នុងផ្លូវដែលនាំឱ្យមានសេចក្តីសុខចម្រើន រក្សាសាមគ្គីធម៌ក្នុងវង្សត្រកូលកុំឱ្យបែកបាក់។

**ទី៤ ប្រតិបត្តិចំពោះសម្បត្តិ** គឺចេះលៃលករក្សាកេរមរតកដែលជាសម្បត្តិបានទទួលពីមាតាបិតាឱ្យបានគង់វង្សចម្រុងចម្រើន មិនឱ្យវិនាស។

**ទី៥ ប្រគល់ទក្ខិណាទាន** គឺកាលដែលមាតាបិតាចង់ធ្វើបុណ្យកុសលណាមួយ កូនត្រូវចាត់ចែងជូនមាតាបិតា។ លុះមាតាបិតាអនិច្ចកម្មទៅ ត្រូវធ្វើទក្ខិណានុប្បទាន គឺជាកិច្ចឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធមាតាបិតាកុំបីខាន ទៅតាមលំអានប្រពៃណីនៃពុទ្ធសាសនិក។

ក្នុងតថភាពសង្គមខ្មែរ ការតបស្នងសងគុណមាតាបិតាគឺជាករណីយកិច្ចរបស់បុត្រធីតាទាំងឡាយ។ ករណីយកិច្ចទាំង៥ខាងលើ ជាអំពើដែលសម្តែងចេញនូវកតញ្ញូកតវេទិតាធម៌របស់កូន ចំពោះមាតាបិតា។ បុត្រធីតាទាំងឡាយតែងរឭកនឹកឃើញដល់គុណមាតាបិតាជានិច្ចដែលជាឥទ្ធិពលនៃព្រះពុទ្ធសាសនា។ ក្នុងពេលមាតាបិតាមានវ័យចាស់ជរា បុត្រធីតាទាំងឡាយតែងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបម្រុង និងតបស្នងសងគុណ។ កាលបើលោកចែកឋានទៅកាន់បរលោក បុត្រធីតាតែងធ្វើបុណ្យតាមប្រពៃណីឧទ្ទិសកុសលជូនមិនដែលអាក់ខានឡើយ។ ព្រះសង្ឃខ្មែរតែងទេសនាប្រដៅពុទ្ធបរិស័ទកុំឱ្យភ្លេចបូជាព្រះកន្លោង។ បើយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅវត្ត កុំភ្លេចថ្វាយព្រះកន្លោងជាមុនសិន ហើយបើថ្វាយបង្គំព្រះសង្ឃនៅវត្ត ចូរកុំភ្លេចថ្វាយបង្គំព្រះកន្លោងជាមុនសិនជាដើម។

### ១.២.៣- សីលធម៌ខាងប្រពន្ធ-ប្ដី

ដើម្បីបានសេចក្ដីសុខសប្បាយត្រជាក់ត្រជុំក្នុងគ្រួសាររវាងស្វាមី និងភរិយានោះ នៅក្នុង*អធិប្បាយសិង្គាលកសូត្រ* ដែលដកស្រង់ពីព្រះត្រៃបិដកភាគ១៩ ព្រះពុទ្ធបរមគ្រូបានត្រាស់សម្ដែងអំពីតួនាទីស្វាមីត្រូវទំនុកបម្រុងភរិយាដោយកិច្ច៥យ៉ាង ចំណែកឯភរិយាក៏ត្រូវអនុគ្រោះស្វាមីវិញដោយកិច្ច៥យ៉ាងដូចគ្នា[16]។

ក- កិច្ច៥យ៉ាងដែលស្វាមីត្រូវទំនុកបម្រុងភរិយា

ទី១ ស្វាមីគប្បីស្រឡាញ់ភរិយាដោយស្មោះ ហើយគប្បីលើកតម្កើងភរិយាឱ្យពេញលក្ខណៈ

ទី២ ស្វាមីមិនត្រូវមើលងាយភរិយាទេ

ទី៣ ស្វាមីមិនត្រូវប្រព្រឹត្តក្បត់ចិត្តភរិយា

ទី៤ ស្វាមីត្រូវប្រគល់សិទ្ធិឱ្យភរិយាជាធំនៅក្នុងផ្ទះរបស់ខ្លួន

ទី៥ ស្វាមីត្រូវឧស្សាហ៍ធ្វើអំណោយដល់ភរិយាខ្លួន មានការជូនគ្រឿងអលង្ការជាដើម។

ខ- កិច្ច៥យ៉ាងដែលភរិយាត្រូវអនុគ្រោះស្វាមីវិញ

ទី១ ភរិយាត្រូវចាត់ចែងការងារផ្ទះដោយល្អ

ទី២ ភរិយាត្រូវសង្គ្រោះជនជាញាតិទាំងពីរខាងដោយមិនប្រកាន់ ឬធ្មើងឆ្មៃ

ទី៣ ភរិយាមិនត្រូវប្រព្រឹត្តក្បត់ចិត្តស្វាមី

ទី៤ ភរិយាត្រូវថែទាំទ្រព្យដែលស្វាមីរកបាន

ទី៥ ភរិយាជាអ្នកឈ្លាស មិនខ្ជិលច្រអូសក្នុងកិច្ចទាំងពួង។

ការស្គាល់ពីតួនាទីទាំងឡាយសម្រាប់សង្គមគ្រួសាររវាងប្ដី និងប្រពន្ធ តាមរយៈការចេះសន្ដោសគ្នាទៅវិញទៅមកដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តិមកនេះ គឺជាកត្តានាំឱ្យសង្គមគ្រួសារជួបប្រទះនូវសេចក្ដីសុខសប្បាយរីករាយ ហើយមិនអាចនឹងមានឧបសគ្គណាមួយធ្វើឱ្យគ្រួសារ ឬភាពជាប្ដីប្រពន្ធមានភាពប្រេះឆានឹងគ្នាឡើយ ពោលគឺគ្រួសារនឹងមានសុភមង្គលពេញលេញ។

### ១.៣- ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ចំពោះវិជ្ជាជីវៈ

នៅក្នុងការប្រកបរបរចិញ្ចឹមជីវិត ព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់បានបញ្ញត្តិក្នុងអដ្ឋង្គិកមគ្គទាំង៨ ត្រង់ "សម្មាអាជីវោ" ដោយបានទូន្មានឱ្យបុគ្គលគ្រប់រូបគប្បីចិញ្ចឹមជីវិតឱ្យបានត្រឹមត្រូវ មានអាជីពត្រឹមត្រូវ ឬមុខរបរសុចរិត ហើយវៀរចាកការចិញ្ចឹមជីវិតខុសដែលមានជំនួញ៥ប្រការ [17] ។

ជំនួញទាំង៥ប្រការនោះមានដូចជា ទី១ ជំនួញសាស្ត្រាវុធ(សត្ថវណិជ្ជ), ទី២ ជំនួញមនុស្ស(សត្តវណិជ្ជ), ទី៣ ជំនួញសត្វដែលគេពិឃាដយកសាច់(មំសវណិជ្ជ), ទី៤ ជំនួញទឹកស្រវឹង(មជ្ជវណិជ្ជ) និងទី៥ គឺជំនួញថ្នាំពុល(វិសវណិជ្ជ)។ ជំនួញទាំងប្រាំខាងលើនេះ ព្រះសម្មាសម្ពុទ្ធបានណែនាំពុទ្ធបរិស័ទមិនគប្បីជួញឡើយ ព្រោះជាហេតុនាំមកនូវអសន្តិសុខ បាត់បង់ស្ថេរភាពនៅក្នុងសង្គមជាតិ។

---

[16] *វិនយប្បញ្ញោ ដុង សុភឿន, សិង្គាលកសូត្រអរិយវិន័យធម៌សម្រាប់ការរស់នៅប្រចាំថ្ងៃក្នុងសង្គម, ឆ្នាំ២០១៣, ទំ. ៨៨-៩៥*

[17] *បិដកលេខ៤៥, ទំ.១៦០*

យើងសូមលើកយក គ្រឿងសាស្ត្រាវុធ គឺជាអាវុធដែលអាចប្រហារជីវិតបានយកមកធ្វើជាឧទាហរណ៍ទៅចុះ។ មនុស្សបានប្រើប្រាស់សាស្ត្រាវុធ ដើម្បីសម្លាប់សត្វ យកសាច់ជាអាហារ។ គេក៏អាចប្រើសាស្ត្រាវុធយកទៅប្រព្រឹត្តបទឧក្រិដ្ឋ បង្កគ្រោះថ្នាក់ផ្សេងៗទៅតាមប្រភេទសាស្ត្រាវុធនីមួយៗ។ ជាតឹកតាង ការប្រើប្រាស់សាស្ត្រាវុធក្នុងសង្គ្រាមលោកលើកទី១ និងលើកទី២ បានសម្លាប់មនុស្សអស់ជាច្រើនម៉ឺននាក់ និងបង្កវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់សង្គម និងសេដ្ឋកិច្ច។

ដូច្នេះ ដើម្បីឱ្យជីវិតរស់នៅមានសេចក្ដីសុខ គ្មានទុក្ខទោស ឬការបៀតបៀនយាយីគ្នាទៅវិញទៅមក ព្រះពុទ្ធបានបង្ហាញផ្លូវមនុស្សឱ្យចិញ្ចឹមជីវិតដោយបរិសុទ្ធប្រកបដោយសីល គឺអាជីវកម្មត្រឹមត្រូវដែលមិនធ្វើឱ្យអ្នកដទៃក្ដៅក្រហាយដោយសារមុខរបររបស់ខ្លួន គឺ "**មុខរបរសុចរិត**"។

## ១.៤- ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ចំពោះសង្គម

ការគោរពជីវិតអ្នកដទៃ ជាតម្លៃមួយដែលទាក់ទងនឹងគ្រប់ផ្នែកទាំងអស់នៃជីវភាពរស់នៅ។ គ្រប់មនុស្សទាំងអស់ ត្រូវតែចេះគោរព និងស្រឡាញ់ជីវិតអ្នកដទៃឱ្យដូចជាស្រឡាញ់ជីវិតខ្លួនឯងដែរ។ យ៉ាងណាមិញ សិក្ខាបទដែលមានចែងក្នុងពុទ្ធវចនៈសុទ្ធតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងមាត្រាមួយចំនួននៃសេចក្ដីថ្លែងការណ៍ជាសកលស្ដីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ [18] ។

ព្រះពុទ្ធសាសនាបានទទួលស្គាល់សិទ្ធិ និងករណីយកិច្ចរបស់មនុស្សតាំងពីជាង២៥០០ឆ្នាំមកហើយ។ ព្រះអង្គបានប្រាប់ និងបានដោះស្រាយបញ្ហាគ្រប់បែបយ៉ាង ដោយប្រើធម៌អហិង្សាមាន មេត្តា ករុណា ពោលគឺមិនប្រើហិង្សាឡើយ។ សីល៥ ឬនិច្ចសីលដែលយើងចេះចាំស្ទើរតែទាំងអស់គ្នា គឺជាការធានានូវសិទ្ធិ និងករណីយកិច្ចរបស់មនុស្សសត្វគ្រប់ៗគ្នាដែលមានទំនាក់ទំនងដូចតទៅ ៖

**បាណាតិបាត** សិក្ខាបទនេះទាក់ទងនឹងសិទ្ធិរស់រានមានជីវិត និងករណីយកិច្ចត្រូវគោរពជីវិតទាំងអស់ ព្រោះម្នាក់ៗគ្មានស្រឡាញ់អ្វីស្មើនឹងជីវិតរបស់ខ្លួនទេ។ ដូច្នេះ សីលទីមួយ គឺការមិនសម្លាប់បៀតបៀនជីវិតអ្នកដទៃ ដើម្បីរស់នៅបានយូរ មានអាយុវែង។

**អទិន្នាទាន** ទាក់ទងនឹងភាពជាម្ចាស់កម្មសិទ្ធិ គ្មាននរណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិដោយបំពានឡើយ។ ដូច្នេះ ចូរកុំលួច កុំប្លន់ កុំបោកប្រាស់ កុំស៊ីសំណូកសូកប៉ាន់ កុំពុករលួយ។ ម្នាក់ៗមានកម្មសិទ្ធិឯកជន។ បើជាតិមានកម្មសិទ្ធិដែលជារបស់ជាតិនិងរបស់រដ្ឋ ដែលជាសម្បត្តិរួមរបស់យើងទាំងអស់គ្នា ហើយយើងត្រូវចាំថា បើយើងចង់ឱ្យគេគោរពកម្មសិទ្ធិរបស់យើង នោះយើងក៏ត្រូវតែគោរពកម្មសិទ្ធិគេវិញផងដែរ។

**កាមេសុមិច្ឆាចារ** គឺត្រូវគោរពសិទ្ធិទាក់ទងបុរស ស្ត្រី កុំរំលោភ កុំបៀតបៀនប្រពន្ធប្ដីអ្នកដទៃ ទុកឱ្យគេរស់នៅបានសុខសាន្ត នោះគេក៏នឹងគោរព មិនបៀតបៀនយើង ទុកឱ្យយើងរស់ដោយសុខសាន្តផងដែរ។

**មុសាវាទ** គឺមនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្ដែងមតិយោបល់។ ប៉ុន្តែមានករណីយកិច្ចកុំកុហក កុំបោកប្រាស់ កុំបរិហារកេរ្តិ៍ កុំញុះញង់ជាដើម។ យើងមានសិទ្ធិចង់បានតែព័ត៌មានពិត

[18] *សេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិមនុស្សត្រូវបានប្រកាសនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ មានចំនួន៣០មាត្រា*

ដូច្នេះយើងក៏ត្រូវតែនិយាយពិត។

**សុរាមេរ័យ** គឺការមិនសេពគ្រឿងស្រវឹង គ្រឿងញៀនដែលធ្វើខូចស្មារតី នាំប្រព្រឹត្តមិនល្អ មានការយល់ខុស និយាយខុសជាដើម គឺនាំឱ្យរក្សាសីលទាំង៤ខាងដើមមិនបាន។ សិក្ខាបទនេះ ទាក់ទងនឹងសិទ្ធិក្នុងការរស់នៅប្រកបដោយសេចក្ដីថ្លៃថ្នូរ និងសុចរិត។

ដូច្នេះ ក្នុងសីល៥ ឬនិច្ចសីល បាននិយាយពីសិទ្ធិផង និងករណីយកិច្ចផង ហើយយើងក៏មិនអាចនិយាយពីសិទ្ធិ ដោយមិននិយាយពីករណីកិច្ចនោះឡើយ។ ក្នុងសេចក្ដីថ្លែងការណ៍ជាសកលអំពីសិទ្ធិមនុស្ស គ្មាននិយាយអ្វីផ្សេងក្រៅពីការនិយាយអំពីការស្រឡាញ់រាប់រកគ្នាជាបងប្អូន រៀនរស់នៅ រៀនធ្វើការ រៀនធ្វើការដោះស្រាយដោយសន្តិវិធី(អហិង្សា) គឺថាប្រកបដោយ មេត្តា ករុណា និងបញ្ញា។ មជ្ឈិមប្បដិបទាក្ដី សីល៥ក្ដី ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងមក ជាសេចក្ដីថ្លែងការណ៍ជាសកលអំពីសិទ្ធិ និងករណីកិច្ចរបស់មនុស្សដ៏ថ្លៃថ្លាបំផុត។ បើគេប្រតិបត្តិតាមមជ្ឈិមប្បដិបទា និងសីល៥ គេមិនអាចរំលោភលើសិទ្ធិមនុស្សបានទេ។ ដូច្នេះ អ្នកដែលមិនរំលោភលើសិទ្ធិមនុស្ស ទោះបីជាជាតិអ្វីក៏ដោយ រស់នៅកន្លែងណាក៏ដោយ ឈ្មោះថាជាបុគ្គលល្អ ជាអ្នកកាន់ព្រះពុទ្ធសាសនា។

ជារួមមកវិញ រាល់សេចក្ដីណែនាំស្ដីពីសិទ្ធិមនុស្ស និងទ្រឹស្ដីព្រះពុទ្ធសាសនា គឺសំដៅដឹកនាំមនុស្សឱ្យក្លាយជាធនធានដ៏ល្អសម្រាប់សង្គម។ សង្គមល្អត្រូវផ្ដើមចេញចេញពីសីលធម៌បុគ្គល។ សង្គមអាចឈានទៅរកសន្តិភាព វឌ្ឍនភាពទៅបាន ដរាបណាមនុស្សចេះគោរពសិទ្ធិមនុស្ស និងមានសីលធម៌ចំពោះសង្គម។

## ២- តួនាទីព្រះពុទ្ធសាសនាចំពោះសង្គម

### ២.១- ព្រះពុទ្ធសាសនា ព្រះសង្ឃ និងវត្តអារាម

សម្រាប់ប្រជាជនខ្មែរ វត្តអារាមជាទីពឹង ទីពំនាក់ ជាបង្អែកខាងផ្លូវចិត្ត ជាកន្លែងសម្រាប់ផ្ដល់នូវបុណ្យកុសលគ្រប់បែបយ៉ាង។ ប្រជាពលរដ្ឋខ្មែរតែងតែប្រារព្ធកម្មវិធីផ្សេងៗដែលជាប្រពៃណីរបស់ព្រះពុទ្ធសាសនាក្ដី ជាទំនៀមទម្លាប់របស់ប្រជាពលរដ្ឋក្ដី នៅតាមទីវត្តអារាម។ វត្តអារាមក៏ជាទីពំនាក់អាស្រ័យរបស់អ្នកដែលគ្មានទីពឹងដូចជា កុមារកំព្រា ចាស់ជរា ជាទីស្នាក់អាស្រ័យរបស់សិស្សានុសិស្ស ជាកូនចៅរបស់ប្រជារាស្ត្រក្រីក្រ។ ជាក់ស្ដែង ថ្នាក់ដឹកនាំយើងមួយចំនួនមាន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាដើម ដែលកាលពីអតីតកាល លោកសុទ្ធតែបានស្នាក់នៅ និងបន្តការសិស្សារៀនសូត្រនៅតាមវត្តអារាម។

ប្រជាជនខ្មែរយើងមានជំនឿលើវត្តអារាមថា វត្តអារាមជាមន្ទីរពេទ្យសម្រាប់ព្យាបាលជំងឺផ្លូវចិត្ត និងជំងឺផ្សេងៗទៀត។ ព្រះសង្ឃខ្លះមានវិជ្ជាចេះផ្សំថ្នាំបុរាណតាមបែបប្រពៃណីយ៉ាងពូកែស័ក្ដិសិទ្ធិ។ វត្តជាឃ្លាំងផ្ទុកនូវចំណេះដឹង វត្តជាបណ្ណាល័យ វត្តជាសារមន្ទីរនៃវប្បធម៌ និងអក្សរសាស្ត្រជាតិនៅគ្រប់សម័យកាល។ ជាពិសេស វត្តជាកន្លែងសិក្សាវិជ្ជាផ្សេងៗដូចជា អក្សរសាស្ត្រ លេខនព្វន្ធ និងចំណេះដឹងផ្សេងៗដែលចាំបាច់សម្រាប់ប្រើក្នុងជីវិត។ អ្នកនិពន្ធថ្មីៗរបស់យើងមួយចំនួន និងសិល្បករល្បីៗពីជំនាន់បុរាណ ក៏បានទទួលការបណ្ដុះបណ្ដាលនៅតាមវត្តអារាមដែរ។ ក្រៅពីនោះ វត្តអារាមក៏ជាតុលាការរបស់ប្រជារាស្ត្រនៅក្នុងភូមិឃុំ គឺពេលណាប្រជារាស្ត្រមានទំនាស់ទាស់ទែងខ្វែងគំនិតគ្នាក្នុងគ្រួសារក្ដី រវាងញាតិសន្តានក្ដី គឺព្រះសង្ឃក៏រួម

ចំណែកជួយដោះស្រាយ ដោយបិណ្ឌបាតនូវសេចក្តីលោភៈ សេចក្តីក្រេវក្រោធ និងកំហឹងដែលពោរពេញទៅដោយហិង្សាទាំងឡាយទាំងពួង ចេញពីបុគ្គលនោះផងដែរ។

ចំណែកព្រះសង្ឃគ្រប់វត្តអារាមទាំងអស់ក្នុងប្រទេស តែងតែអប់រំប្រជាពលរដ្ឋ ក្នុងស្រុកភូមិ ទាំងទ្រឹស្តី ទាំងការពិសោធន៍។ ការអប់រំផ្នែកទ្រឹស្តី និងស្មារតី គឺការអប់រំតាមរយៈការសម្តែងធម៌ទេសនានៅតាមវិទ្យុ ទូរទស្សន៍ បណ្តាញសង្គម និងសឹងតែគ្រប់ពិធីបុណ្យទាំងអស់ ជាពិសេសគឺនៅក្នុងពិធីបុណ្យសព។ ព្រះសង្ឃតែងតែទេសនាពន្យល់អំពីទ្រឹស្តីនៃការកើត ចាស់ ឈឺ ស្លាប់ តាមច្បាប់ធម្មជាតិ(វាលវដ្តសង្សារ) ដើម្បីឱ្យពលរដ្ឋស្គាល់ច្បាស់នូវបញ្ហាជីវិត និងចេះបន្ធូរបន្ថយនូវមរណទុក្ខ អំពីចិត្តគំនិតគ្រួសារសពផង ឱ្យយល់ហេតុផល អានិសង្សនៃការជួយសង្គ្រោះផង ដោយសម្ភារៈចំពោះអ្នកកំពុងទទួលមរណទុក្ខផង ដើម្បីឱ្យមានសាគ្គីធម៌ផង ចេះជួយទុក្ខធុរៈគ្នាក្នុងស្រុកភូមិផង។ រីឯការអប់រំដោយការអនុវត្ត និង ពិសោធន៍វិញ គឺព្រះសង្ឃមិនគ្រាន់តែសូត្រធម៌ទេសនាពន្យល់ត្រឹមទ្រឹស្តីប៉ុណ្ណោះទេ បើមានបុគ្គលណាមួយឬក្រុមគ្រួសារណាមួយក្នុងស្រុកភូមិមានគ្រោះវិបត្តិផ្សេងៗដូចជា គ្រោះទុរ្ភិក្ស គ្រោះរាំងស្ងួត ភ្លើងឆេះផ្ទះ។ល។ លោកតែងទៅនិមន្តចូលរួមឧបត្ថម្ភទាំងខាងផ្លូវចិត្ត និងសម្ភារៈដូចជា អង្ករ ត្រីសាច់ ចាន ឆ្នាំង គ្រឿងឧបភោគ និងបរិភោគ ជាដើម តាមដែលព្រះសង្ឃលោកមានលទ្ធភាពអាចធ្វើទៅបាន ហើយការអប់រំនេះ ទទួលបានផលល្អបំផុត ក៏កើតជាប្រពៃណីចាំបាច់មួយក្នុងសង្គមខ្មែរ។ គ្រប់កិច្ចការទាំងអស់ក្នុងស្រុកភូមិ ទោះក្នុងវត្តក្តី ក្រៅវត្តក្តី ដូចជាការកសាងព្រះវិហារ កុដិ សាលា ផ្លូវ ស្ពាន ជីកស្រះ អណ្តូង ការធ្វើពិធីក្នុងរដូវភ្ជុំបិណ្ឌ កឋិន ចូលឆ្នាំជាដើម សុទ្ធតែជាការអប់រំប្រជាពលរដ្ឋ ឱ្យយល់ចេះដឹងនូវគោលការណ៍មនុស្សធម៌ សីលធម៌ ចេះចែករំលែក ជួយសង្គ្រោះ។ល។ ប្រជាពលរដ្ឋខ្មែរតែងយល់ដឹង និងចងចាំជាទូទៅថា "**ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប**" ឬ "**ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់**"។

ពុទ្ធសាសនិកតែងក្រេបជញ្ជក់ព្រះធម៌ពីព្រះសង្ឃតាមគន្លងក្រឹត្យក្រមវិន័យរបស់ព្រះពុទ្ធជាម្ចាស់។ វត្តអារាមនៃពុទ្ធសាសនាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិនឹងឧបាសក-ឧបាសិកា ដែលមានចាស់ទុំជាអាចារ្យផ្សារភ្ជាប់នៅក្នុងសង្គមគ្រួសារ។ ចាស់ព្រឹទ្ធាចារ្យបានបន្តអប់រំដំបូន្មានប្រកបដោយធម៌ ដល់សមាជិកគ្រួសារផ្ទាល់ និងបុគ្គលផ្សេងៗទៀត។ តាមរយៈវត្តអារាម បានធ្វើឱ្យសង្គមខ្មែរមានឧត្តមគតិស្នេហាជាតិមាតុភូមិ យល់ដឹងអំពើល្អ មានសាមគ្គីធម៌ ចេះឱ្យតម្លៃជីវិត ប្រកាន់នូវមេត្តាធម៌ ករុណា សន្តោសប្រណី បណ្តុះវប្បធម៌អហិង្សានៅក្នុងសង្គមជាដើម។

ដូច្នេះយើងមើលឃើញថា ព្រះសង្ឃនៅគ្រប់វត្តអារាមទាំងអស់មាននាទីសំខាន់ណាស់ក្នុងការជួយអប់រំពលរដ្ឋគ្រប់មធ្យោបាយតាមលទ្ធភាពដែលព្រះសង្ឃអាចធ្វើទៅបាន តាមធម៌វិន័យពុទ្ធសាសនា តាមការសម្តែងធម្មទេសនា ការចែករំលែកទានដែលបរិស័ទប្រគេនដល់ជនរងគ្រោះ។ ចំណុចនេះ សុទ្ធតែជាចំណែកក្នុងការលើកម្ពស់សីលធម៌ និងចរិយាធម៌ដល់សង្គមមនុស្សទាំងអស់ ទោះបីដោយផ្ទាល់ក្តី ដោយប្រយោលក្តី។ ស្ថិតក្នុងន័យនេះ សបញ្ជាក់ឱ្យកាន់តែច្បាស់ថា ព្រះពុទ្ធសាសនាមានតម្លៃណាស់សម្រាប់សង្គម។

## ២.២- ព្រះពុទ្ធសាសនា និងសាលារៀន

បច្ចុប្បន្ននេះ ព្រះពុទ្ធសាសនាបានផ្សារភ្ជាប់យ៉ាងស្អិតរមួតជាមួយនឹងសាលារៀន និងគ្រឹះស្ថានអប់រំនានា។ ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងយកចិត្តទុកដាក់ក្នុងការអប់រំសីលធម៌ ផ្សារភ្ជាប់នឹងព្រះពុទ្ធសាសនានៅតាមសាលារៀន ដូចជាមានការសូត្រធម៌នមស្ការព្រះរតនត្រ័យនៅក្រោយការគោរពទង់ជាតិ ការសមាធិមុនម៉ោងសិក្សា។ល។ បើយោងតាម *សេចក្តីណែនាំលេខ៦០ អយក.សណន របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីដំណើរការគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈក្នុងឆ្នាំសិក្សា២០២៣-២០២៤ ក្នុងក្របខណ្ឌស្តង់ដាសាលារៀនគំរូ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ត្រង់ចំណុចទី៤.២.៦-កម្មវិធីផ្សេងៗទៀត* ក្រសួងបានធ្វើការណែនាំឱ្យគណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូសហការជាមួយវត្តអារាមរៀបចំឱ្យមានការនិមន្តព្រះសង្ឃចូលរួមកម្មវិធីអប់រំផ្លូវចិត្តដល់លោកគ្រូអ្នកគ្រូ សិស្សានុសិស្សផ្តោតលើសីល សមាធិ បញ្ញា ជាការយល់ដឹងនូវដំណើរ និងធម្មជាតិនៃជីវិត។ មួយវិញទៀតនោះ តាមរយៈហ្វេសបុកផេកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា(MoEYS Cambodia) ក៏តែងតែចែករំលែកវីដេអូអប់រំបែបព្រះពុទ្ធសាសនា ទស្សនៈអប់រំបែបព្រះពុទ្ធសាសនារបស់ព្រះភិក្ខុវជិរប្បញ្ញោ គូ សុភាព ជាដើម ដែលជាចំណែកក្នុងការលើកកម្ពស់សីលធម៌ និងចរិយាធម៌នៅក្នុងសង្គមកម្ពុជា។ ស្របគ្នានេះដែរ កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ ថ្មីៗកន្លងទៅនេះ ហ្វេសបុកផេករបស់ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការចែករំលែករូបភាពមួយចំនួនក្រោមប្រធានបទ "ការសម្តែងធម្មទេសនាអប់រំសីលធម៌សង្គម និងឥរិយាបថយុវជនប្រកបដោយសីល សមាធិ បញ្ញា" ដល់សិស្សចំនួន២០២៦នាក់ នៅវិទ្យាល័យពោធិសាត់ ហើយសកម្មភាពអប់រំបែបព្រះពុទ្ធសាសនាកំពុងតែផុសផុលនៅតាមសាលារៀននីមួយៗទូទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ។

ក្រៅពីនេះ ដើម្បីលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌តាមរយៈព្រះពុទ្ធសាសនា ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដាក់បញ្ចូលស្នាដៃអក្សរសល្ប៍ពុទ្ធនិយមមួយចំនួនដែលជាស្នាដៃទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា ទៅក្នុងកម្មវិធីសិក្សាថ្នាក់មធ្យមសិក្សាចំណេះទូទៅចាប់ពីថ្នាក់ទី១០ ដល់ទី១២ផងដែរ។ ក្នុងនោះ ចំពោះថ្នាក់ទី១០មានដូចជា រឿងសិរីជរ ចន្ទរាជា ព្រះវេស្សន្តរ[19] តេមិយ សុបិនកុមារ។ ចំពោះថ្នាក់ទី១១ មានរឿងសុវណ្ណសាម និងថ្នាក់ទី១២ មានរឿងព្រះវេស្សន្តរ និងហង្សយន្ត។ រាល់ស្នាដៃនីមួយៗសុទ្ធតែបង្កប់នូវទស្សនវិជ្ជាពុទ្ធសាសនាក្នុងការអប់រំសីលធម៌ និងចរិយាធម៌ដល់សិស្សានុសិស្ស។ តួយ៉ាងតាមរយៈរឿងសុវណ្ណសាមជាតក ផ្ទៃរឿងបានបង្ហាញអំពីគុណធម៌របស់តួអង្គដែលអាចឱ្យសិស្សានុសិស្សយកតម្រាប់តាមបាន។ តួអង្គសុវណ្ណសាមបានបំពេញកាតព្វកិច្ចបម្រើមាតាបិតាដោយសេចក្តីត្រេកអរ ដ្បិតលោកទាំងពីរជាអ្នកមានគុណសមដូចពុទ្ធដីកាដែលលើកឡើងថា "**មាតាបិតាជាព្រះកន្លោង**"។ ចំណែករឿងព្រះវេស្សន្តរបានបណ្តុះស្មារតីសិស្សានុសិស្សឱ្យចេះស្រឡាញ់អំពើល្អ ចេះបរិច្ចាគទាន ជួយសង្គ្រោះដល់ជនកម្សត់ទុរគត ឬជនជួបគ្រោះអាសន្ននានា។ តួអង្គព្រះវេស្សន្តរមិនសំងំយកសុខតែឯង ដោយព្រះអង្គសុខចិត្តលះបង់ដំរី

---

[19] *សេចក្តីណែនាំលេខ០៣ អយក.សណន របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៦ តម្រូវឱ្យកែាត អត្ថបទរឿងទាំងមូលនៅថ្នាក់ទី១១*

បច្ច័យនាគេន្ទ្រដែលជាដំរីមង្គលដល់អ្នកស្រុកកលិង្គរាស្ត្រ។ ត្រង់នេះ អាចឱ្យសិស្សានុសិស្សមើលឃើញពីចិត្តសប្បុរសធម៌ មនុស្សធម៌របស់ព្រះវេស្សន្តរក្នុងនាមជាបុគ្គលនៅក្នុងសង្គមដោយមិនអាចឈរមើលមនុស្សជាតិទាំងមូលស្លាប់ដោយការដាច់ស្បៀងនោះឡើយ។ ការណ៍នេះ ជាការចូលរួមវិភាគទានមួយយ៉ាងសំខាន់ក្នុងការបណ្តុះនិស្ស័យមនុស្ស ក៏ដូចជាយុវជនជំនាន់ក្រោយឱ្យស្គាល់អំពើល្អ ចេះសាងកុសល ដើម្បីជីវិតរស់នៅបានសេចក្តីសុខ ស្របនឹងពុទ្ធភាសិតថា "**សុខោ បុញ្ញស្ស ឧច្ចយោ**"។

## ២.៣- ព្រះពុទ្ធសាសនា និងកិច្ចអភិវឌ្ឍប្រទេសជាតិ

ក្រៅអំពីការអប់រំបណ្តុះបណ្តាលឱ្យមនុស្សប្រព្រឹត្តតែក្នុងផ្លូវល្អ សាងតែកុសល ព្រះពុទ្ធសាសនាក៏ជាស្ថាបនិកដ៏សំខាន់ក្នុងកិច្ចការកសាងមាតុភូមិដែរ។ វិស័យព្រះពុទ្ធសាសនាបានជួយឧបត្ថម្ភគាំទ្រដល់ការកសាងសាលារៀន មន្ទីរពេទ្យ អង្គការមនុស្សធម៌ ការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គម( ស្ពាន ថ្នល់ វត្តអារាម សាលាសំណាក់ អណ្តូងទឹក...)។ ឥទ្ធិពលនៃទ្រឹស្តីព្រះពុទ្ធសាសនាបានជ្រួតជ្រាបចូលក្នុងសន្តានចិត្តនៃប្រជាជនខ្មែរ។ ប្រការនេះ ធ្វើឱ្យពុទ្ធបរិស័ទកើតមានសទ្ធាជ្រះថ្លា ហើយជួយដោយបរិច្ចាគចេតនាក្នុងកិច្ចការអភិវឌ្ឍសង្គមជាតិ។ មិនតែប៉ុណ្ណោះ សមិទ្ធផលដែលបង្កប់នូវសិល្បៈវប្បធម៌ជាតិក៏បានដុះដាលឡើងតាមរយៈវិស័យព្រះពុទ្ធសាសនា មានវិហារ កុដិ សាលា ការកសាងពុទ្ធិកបឋមសិក្សា ពុទ្ធិកវិទ្យាល័យ ពុទ្ធិកសាកលវិទ្យាល័យជាដើម សម្រាប់ព្រះសង្ឃសិក្សារៀនសូត្រ។ លើសពីនេះ នៅតាមវត្តអារាមនៃព្រះពុទ្ធសាសនា ប្រៀនបាននឹងឧទ្យាន ជាទីរមណីយប្រកបដោយរុក្ខជាតិតូចធំប្រកបដោយសោភណភាព ដែលបានក្លាយជាគំរូដ៏ល្អប្រពៃក្នុងការរួមចំណែកអភិវឌ្ឍជនបទជាមួយរដ្ឋាភិបាល។

តាមរយៈលទ្ធផលទាំងនេះ យើងអាចនិយាយបានថា "**ព្រះពុទ្ធសាសនាជាស្ថាបនិកក្នុងកិច្ចអភិវឌ្ឍប្រទេសជាតិ**"។ ប្រទេសជាតិបានទទួលវឌ្ឍនភាព រីកចម្រើនលូតលាស់ គឺអាស្រ័យដោយមានការរួមចំណែកពីព្រះពុទ្ធសាសនា។

## IV- សន្និដ្ឋាន

ជារួមមក តាមរយៈការបកស្រាយពី "តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌" ខាងលើនេះ ធ្វើឱ្យយើងមើលឃើញកាន់តែច្បាស់ថា ព្រះពុទ្ធសាសនាពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រជាជនខ្មែរ ក៏ដូចជាប្រទេសជាតិទាំងមូល។ សាសនាដ៏ល្អនេះបានរួមចំណែកកសាង បណ្តុះឧបនិស្ស័យមនុស្សឱ្យមានសីលធម៌ គុណធម៌ សុជីវធម៌ និងចេះរស់នៅជាមួយគ្នាក្នុងសង្គមប្រកបដោយសុខសន្តិភាព និងជួយជំរុញការអភិវឌ្ឍសង្គម។ ព្រះពុទ្ធសាសនាបានប្រដៅមនុស្សឱ្យស្គាល់តួនាទីខ្លួនឯង តួនាទីចំពោះមាតាបិតា តួនាទីចំពោះអ្នកដទៃ និងតួនាទីចំពោះសង្គមជាតិ ដើម្បីញ៉ាំងខ្លួនឯងឱ្យមានឈ្មោះថា ជាមនុស្សរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ សក្តិសមជាធនធានដ៏ល្អសម្រាប់សង្គម។ ប្រជាជនខ្មែរ ជាពិសេសពុទ្ធសាសនិកមិនអាចរស់នៅដោយគ្មានពុទ្ធសាសនាបានទេ ព្រោះខ្មែរយើងបានផ្សារភ្ជាប់ជីវិតទៅនឹងព្រះពុទ្ធសាសនាតាំងពីពេលកើត រហូតដល់ស្លាប់ទៅវិញរួចបាត់ទៅហើយ។

មកទល់នឹងពេលបច្ចុប្បន្ន ព្រះពុទ្ធសាសនាមានការរីកចម្រើនជាលំដាប់ស្របតាមដំណើរនៃប្រទេសជាតិមានការអភិវឌ្ឍ ព្រោះព្រះពុទ្ធសាសនាមានទំនាក់ទំនងជាមួយនឹងប្រទេសជាតិ។ ប្រសិនបើប្រទេសមានការអភិវឌ្ឍ នោះព្រះពុទ្ធសាសនាក៏មានការអភិវឌ្ឍ ឬអាចនិយាយបានថា បើផ្នែកអាណាចក្រមានការជឿនលឿន ផ្នែកពុទ្ធចក្រក៏មានភាពខ្ពង់ខ្ពស់ឧត្តុង្គឧត្តមទៅតាមនោះដែរ។ ផ្ដើមចេញពីសារៈសំខាន់ជាវិជ្ជមានរបស់ព្រះពុទ្ធសាសនានៅកម្ពុជា និងស្ថានភាពសេដ្ឋកិច្ចនយោបាយរបស់ប្រទេសជាតិ ទើបបច្ចុប្បន្ននេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមកិច្ចដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក៏បាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាទៅលើវិស័យព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងការអភិវឌ្ឍសង្គម។ ដូច្នេះ កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយ គប្បីដុសខាត់លត់ដំកាយ វាចា ចិត្តឱ្យបានល្អ ចេះធ្វើបុណ្យ រក្សាសីលឱ្យបានខ្ជាប់ខ្ជួន។ ព្រះពុទ្ធទ្រង់បានត្រាស់សម្ដែងថា "***សីលេន សុគតី យន្តិ សីលេន ភោគ សម្បទា សីលេន និព្វុតី យន្តិ***" ប្រែថា សត្វទាំងឡាយបានទៅកាន់ឋានសួគ៌ក៏ព្រោះសីល សត្វទាំងឡាយបានបរិបូរណ៍ដោយភោគៈក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរំលត់ទុក្ខ គឺព្រោះនិព្វានក៏ព្រោះសីល"។

ថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤
បកស្រាយដោយ ៖ យុយ ម៉េងឃី
គ្រូបង្រៀនសាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុនសែន ពាមជីកង

# គន្ថនិទ្ទេស


- ការិយាល័យឧត្តមស្នងការ, កម្រងអនុសាសន៍របស់យន្តការសិទ្ធិមនុស្សសហប្រជាជាតិ ចំពោះព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០១៤
- កែវ អ៊ុន ឬសំអៀន, កម្រងអត្ថបទធម៌ទេសនាស្តីអំពីព្រះពុទ្ធសាសនា, ឆ្នាំ២០១៣
- ក្រសួងយុត្តិធម៌, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០១០
- ក្រសួងអប់រំ យុវជន និងកីឡា, សេចក្តីណែនាំលេខ០៣ អយក.សណន ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្រៀនសិក្សាអត្ថបទអក្សរសិល្ប៍នៅមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ដល់ថ្នាក់ទី១២
- ក្រសួងអប់រំ យុវជន និងកីឡា, សីលធម៌-ពលរដ្ឋវិជ្ជាថ្នាក់ទី១១, គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ, ឆ្នាំ២០១០
- ក្រសួងអប់រំ យុវជន និងកីឡា, សីលធម៌-ពលរដ្ឋវិជ្ជាថ្នាក់ទី១២, គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ, ឆ្នាំ២០១១
- ជា វណ្ណី, តម្លៃអប់រំនៃការបណ្តុះធម្មចរិយា, រាជបណ្ឌិត្យសភាកម្ពុជា, ឆ្នាំ២០២២
- ជី ប៊ុនធឿន, តួនាទីព្រះពុទ្ធសាសនា, ព.ស.២៥៥៦
- ជួន ណាត, វចនានុក្រមខ្មែរ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦៧
- ឈឹម ស៊ុម សទ្ធម្មប្បញ្ញា, កុម្ភជាតក, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៥៨
- ដុង សុភឿន, សិង្គាលកសូត្រអរិយវិន័យធម៌សម្រាប់ការរស់នៅប្រចាំថ្ងៃក្នុងសង្គម, ការផ្សាយរបស់ពុទ្ធកបណ្ឌិត្យសភានៃសកលវិទ្យាល័យបញ្ញាសាស្រ្តកម្ពុជា, ឆ្នាំ២០១៣
- ត្រឹង ងា, អរិយធម៌ខ្មែរថ្នាក់បញ្ចប់(កម្មវិធីថ្មី), ការផ្សាយរបស់អ្នកនិពន្ធ បោះពុម្ពលើកទី៣ ឆ្នាំ១៩៧៥
- ប៉ាង ខាត់, ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ, ពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥០៤
- ប៉ាង ខាត់, វប្បធម៌-អរិយធម៌ខ្មែរ-ឥណ្ឌា, ការផ្សាយរបស់ពុទ្ធិកសិក្សា, ឆ្នាំ១៩៧០
- បិដកលេខ៥៨ និងលេខ៤៥
- លាង ហាប់អាន, ប្រវត្តិអក្សរសាស្រ្តខ្មែរ, បណ្ណាគារ គីម អេង, ឆ្នាំ១៩៦៧
- សូរ ហាយ, កតញ្ញូកតវេទិកថា, ក្រុមជំនុំព្រះត្រៃបិដកពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៥៧
- ហង់ ច័ន្ទវរៈ , សីលរតនៈ, ការផ្សាយរបស់អ្នកនិពន្ធ, បោះពុម្ពលើកទី៣ ឆ្នាំ២០២២
- ហួត តាត, ព្រះពុទ្ធសាសនាសង្ខេបសម្រាប់យុវជនសិក្សា, បណ្ណាគារត្រៃរតន៍, ឆ្នាំ១៩៩៩
- អ៊ីវ ចុង, អត្ថាធិប្បាយអរិយធម៌ខ្មែរ, សមូហកម្ម ឥន យឿន និងក្រុមសៀវភៅ ISB, ឆ្នាំ២០១៥

# ឧបសម្ព័ន្ធ(រូបភាព)



ព្រះសង្ឃសម្តែងធម៌ទេសនាអប់រំពុទ្ធបរិស័ទក្នុងពិធីបុណ្យចម្រើនព្រះជន្ម
(ស្រុកកងមាស ខេត្តកំពង់ចាម)




ព្រះភិក្ខុវជិរប្បញ្ញោ **គូ សុភាព** និមន្តចូលរួមសិក្ខាសាលា "ភាពចាំបាច់នៃសីលធម៌ និងសុចរិតភាព ដើម្បីភាពជោគជ័យក្នុងអាជីព និងជីវិត" នៅសាលាPIS (ក្រុងកំពង់ចាម)



សិស្សានុសិស្សសាលាបឋមសិក្សាអង្គរបាន ជំនាន់ថ្មី ធ្វើសមាធិក្រោយគោរពទង់ជាតិ និងមុនម៉ោងសិក្សា

(ស្រុកកងមាស ខេត្តកំពង់ចាម)





ព្រះតេជគុណ ម៉ាច ម៉េងហុង អតីតសិស្សនៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង និមន្តចូលរួម
ប្រារព្ធពិធីបុណ្យមាឃបូជា និងសម្តែងធម៌ទេសនាពីប្រវត្តិមាឃបូជា និងគុណមាតាបិតា
នៅក្នុងបរិវេណវិទ្យាល័យ ហ៊ុន សែន ពាមជីកង






ការសម្តែងធម្មទេសភាពអប់រំសីលធម៌សង្គម និងឥរិយាបថយុវជនប្រកបដោយសីល សមាធិ បញ្ញា
នៅវិទ្យាល័យពោធិ៍សាត់ ( ប្រភពរូបភាព MoEYS Cambodia )





សិស្សានុសិស្សចូលរួមប្រឡងចំណេះដឹងព្រះពុទ្ធសាសនាអំពីបុណ្យមាឃបូជា

( ប្រភពហ្វេសប៊ុកផេក Kou Sopheap )





ព្រះសង្ឃផ្តល់គ្រឿងឧបភោគបរិភោគ និងថវិកាដល់ជនក្រីក្រ

(ស្រុកកងមាស ខេត្តកំពង់ចាម)





ប្រជាពលរដ្ឋខ្មែរជួបជុំគ្នាធ្វើបុណ្យនៅតាមទីវត្តអារាមប្រកបដោយសទ្ធាជ្រះថ្លា

(វត្តអម្ពវត្យារាម ហៅវត្តស្វាយតាហែន ស្រុកកងមាស ខេត្តកំពង់ចាម)



# ឧបសម្ព័ន្ធ(ឯកសារ)







































ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីណែនាំ

